រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

051KH01A-01

ចូរទុកអោយក្មេងៗមករកខ្ញុំចុះ !



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៥១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត បណ្តុះបណ្តាលឪពុកម្តាយ និង សមាជិកឯទៀត អោយចេះបង្រៀនកុមារ អោយក្លាយទៅជាសិស្សរបស់ព្រះយេស៊ូ ។ ទូលសូមអោយព្រះជាម្ចាស់ជួយអ្នកអនុវត្តតាមរបៀបបង្រៀនកុមារខាងក្រោមនេះ ។

ណែនាំបណ្តុះបណ្តាលឪពុកម្តាយ និង មិត្តភក្តិ អោយបង្រៀនកុមារ



កម្មវិធីបង្រៀន :

១-_____ (នាទី) _____

២-_____ (នាទី) _____

៣-_____ (នាទី) _____

៤-_____ (នាទី) _____

៥-_____ (នាទី) _____

៦-_____ (នាទី) _____

៧-_____ (នាទី) _____

ចំនួនសិស្សដែលចូលរួម :_____ ជង្វាយ :_____

បំពេញបានគោលដៅពិសេសដល់ណា :

អត់សោះ__ មិនសូវល្អ__ ល្អល្មម__ ល្អណាស់__ ទាំងស្រុង__

សេចក្តីត្រូវការ សំណួរ ឬ បញ្ហាដែលត្រូវដោះស្រាយ នៅពេលប្រជុំលើកក្រោយ : _____

© Project WorldReach © SEAN

គំរូអំពីគំរោងមេរៀនសំរាប់បង្រៀនគ្រីស្តជន

ថ្ងៃខែ :_____ក្រុម :_____គ្រូបង្រៀន :_____

អ្នកជំនួយបង្កើតសាវ័ក : _____

គោលដៅទូទៅ : _____

ពេលវេលា : _____ទីកន្លែង : _____

គោលដៅពិសេស :_____

អត្ថបទព្រះគម្ពីរ : _____

ខ្លឹមសារ :_____

_____

វិធីសាស្ត្រ :_____

_____

_____

សម្ភារៈ : _____

_____

_____



© Project WorldReach © SEAN



- ក្លោងទ្វារចូលទៅក្នុងទីក្រុងយេរូសាឡឹម : ម៉ាថាយ ២១:១-១៧
- ការធ្វើពិធីកាច់នំបុ័ង : ម៉ាថាយ ២៦:១៧-២៩
- ព្រះយេស៊ូព្រួយព្រះហឫទ័យខ្លាំង នៅក្នុងសួនកេតសេម៉ានី និង ការចាប់ខ្លួនព្រះអង្គ : ម៉ាថាយ ២៦:៣៦-៥៦
- ការកាត់ទោសព្រះយេស៊ូ : ម៉ាកុស ១៤:៥៥-៦៥, យ៉ូហាន ១៨:២៨-៤០, ១៩:១-១៦
- ការសុគតលើឈើឆ្កាង : យ៉ូហាន ១៩:១៧-៣៧
- ការបញ្ចុះព្រះសពព្រះយេស៊ូទៅក្នុងផ្នូរ : យ៉ូហាន ១៩:៣៨-៤២
- ការមានព្រះជន្មរស់ឡើងវិញ : យ៉ូហាន ២០-២១
- ការយាងឡើងទៅស្ថានបរមសុខ : លូកា ២៤:៥០-៥៣
- ការយាងមកបស់ព្រះវិញ្ញាណដ៏វិសុទ្ធ : កិច្ចការ ២

រឿងដកស្រង់ពីសម្ពន្ធមេត្រីថ្មី

(រឿងខ្លះដែលដកស្រង់ពីសៀវភៅដំណឹងល្អទាំងបួន និង សៀវភៅកិច្ចការ មានរៀបរាប់រួមជាមួយនឹងរឿងរបស់សម្ពន្ធមេត្រីចាស់ដែលនិយាយពីប្រធានបទដូចគ្នា) ។

ព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងសម្ពន្ធមេត្រីថ្មី គឺ :

- កំណើតរបស់ព្រះយេស៊ូ : ម៉ាថាយ ១-២, លូកា ២
- ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ : ម៉ាថាយ ៣
- ព្រះយេស៊ូឈ្នះការល្បួង : ម៉ាថាយ ៤:១-១១
- ព្រះយេស៊ូត្រាស់ហៅសាវ័ករបស់ព្រះអង្គ : ម៉ាថាយ ៤:១៨-២២, ៩:៩-១៣, ម៉ាកុស ៣:១៣-១៩, យ៉ូហាន ១:៣៥-៥១
- សិរីរុងរឿងរបស់ព្រះយេស៊ូ : ម៉ាថាយ ១៧

លោកគ្រូនិយាយត្រូវណាស់ ។ ខ្ញុំនឹងចាត់តាំងមនុស្សខ្លះ អោយជួយបណ្តុះបណ្តាលកុមារម្នាក់ៗ ដែលគ្មានឱពុកម្តាយបង្រៀន អោយក្លាយជាសិស្សរបស់ព្រះយេស៊ូដោយសេចក្តីស្រឡាញ់ ។ ដូច្នេះ ខ្ញុំត្រូវរកអ្នកជំនួយច្រើននាក់សំរាប់ជួយគ្រូបង្រៀន ព្រោះគ្រូបង្រៀនម្នាក់ឯងមិនអាចផ្តល់ដំបូន្មានដល់កុមារគ្រប់គ្នាដោយផ្ទាល់ទេ ។



ត្រូវហើយប្អូន ! ប្អូនត្រូវរៀបចំ “អ្នកបង្កើតសាវ័ក” ដែលនឹងនិយាយជាមួយកុមារយ៉ាងតិចពីរអាទិត្យម្តង ។

© Project WorldReach © SEAN

សូមយកយោបល់ដែលគ្រូគង្វាលផ្តល់អោយវិរៈ ទុកជារបៀប
បង្រៀនព្រះគម្ពីរដ៏ល្អដល់កុមារ :

☐ ជួយឪពុកម្តាយឱ្យអាចបង្រៀនព្រះបន្ទូលដល់កូនៗរបស់គេ ។

☐ ជួយកុមារដែលមានសមត្ថភាពជាងគេ ឱ្យអាចជួយបំពេញ
មុខងារបំរើ (ក្នុងឋានៈជាគ្រូជំនួយ) ខាងការបង្រៀន និង
ខាងការបណ្តុះបណ្តាលកុមារតូចៗ ឱ្យក្លាយជាសិស្សរបស់
ព្រះយេស៊ូ ។

☐ ជួយកុមារ និង ឪពុកម្តាយឱ្យអាចយកព្រះបន្ទូលទៅអនុវត្ត
ក្នុងជីវិតរបស់ខ្លួន ដូចជាទៅសួរសុខទុក្ខកុមារដែលឈឺ
។ល។ ។

☐ ចែកបញ្ជីរឿងរបស់ព្រះគម្ពីរដល់ឪពុកម្តាយ ដើម្បីអោយ
ឪពុកម្តាយនិយាយប្រាប់កុមារនៅផ្ទះ ។ អ្នកអាចឃើញបញ្ជី
រឿងរបស់ព្រះគម្ពីរសំរាប់បង្រៀនកុមារ នៅខាងចុងសៀវ-
ភៅសិក្សានេះ ។

សូមពិនិត្យមើលយោបល់ទាំងនេះឡើងវិញ ហើយគូសសញ្ញា «✓»
នេះ នៅក្បែរយោបល់ដែលអ្នកត្រូវយកទៅអនុវត្ត ។

- ម្រាមដៃសរសេរអក្សរលើជញ្ជាំង : ដានីអែល ៥
(ត្រូវរៀបចំខ្លួនសំរាប់ថ្ងៃជំនុំជំរះ) ។
- ព្រះយេស៊ូទ្រង់ព្រះកន្សែងអាណិតក្រុងយេរូសាឡឹម : លូកា
១៣:៣១-៣៥, ១៩:៤១-៤៤, ២១:៥-៧, ២០-២៤
- លោកដានីអែលនៅក្នុងរូងតោ : ដានីអែល ៦
(ទុកចិត្តលើព្រះជាម្ចាស់ ដែលបានរំដោះយើងចេញពីមារ
សាតាំង) ។
- ការដេញខ្មោចចេញពីបុរស នៅក្នុងតំបន់កេរ៉ាសា : ម៉ាកុស
៥:១-២០
- លោកយ៉ូណាសត្រូវត្រីធំលេប : យ៉ូណាស ១-២
(ទុកចិត្តថា អំណាចរបស់ព្រះជាម្ចាស់នឹងជួយអោយរួចពី
សេចក្តីស្លាប់) ។
- ពួកផារីស៊ីទាមទារអោយបង្ហាញទីសំគាល់អស្ចារ្យ : ម៉ាថាយ
១២:៣៨-៤០
- លោកថូម៉ាសមិនទទួលស្គាល់ព្រះយេស៊ូ ពេលដែលព្រះអង្គ
មានព្រះជន្មរស់ឡើងវិញ : យ៉ូហាន ២០:២៤-២៩

- ព្រះបន្ទូល ដែលលោកយេរេមីប្រកាស ត្រូវគេបដិសេធ : យេរេមី ៣៦-៣៩
(បង្រៀនតែសេចក្តីពិត ទោះបីជាត្រូវបូជាអ្វីក៏ដោយ) ។
- ដំណឹងល្អដែលលោកប៉ូលប្រកាស ត្រូវគេបដិសេធ : កិច្ចការ ២១-២៦
- ឆ្នឹងស្មូត : អេសេគីអែល ៣៧
(ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានជីវិតថ្មីក្នុងព្រះគ្រីស្ត) ។
- ព្រះយេស៊ូត្រូវគេទិតៀន ដោយសារព្រះអង្គប្រោសមនុស្សខ្វិនអោយដើររួច នៅថ្ងៃឈប់សំរាក ។ ហើយព្រះអង្គបានមានព្រះបន្ទូលសន្យាដែរថា ព្រះអង្គនឹងប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ : យ៉ូហាន ៥:១-២៩
- យុវជនបីនាក់នៅក្នុងឡ ដែលមានភ្លើងឆេះសន្ធោសន្ធៅ : ដានីអែល ៣
(ទូលសូមអោយព្រះជាម្ចាស់ជួយការពារជានិច្ច) ។
- សត្រូវស្បថថាមិនបរិភោគ រហូតទាល់តែបានសម្លាប់លោកប៉ូល : កិច្ចការ ២៣:១២-៣៣

ហេតុអ្វីបានជាត្រូវយកចិត្តទុកដាក់គិតអំពីកុមារ ?

ឪពុកម្តាយជាគ្រីស្តជនត្រូវអធិស្ឋានសំរាប់កូនៗខ្លួន ដោយប្រកាសសេចក្តីសន្យារបស់ព្រះបន្ទូល : *« សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោក ព្រមទាំងសង្គ្រោះក្រុមគ្រួសារ របស់លោកផងដែរ »* (កិច្ចការ ១៦:៣១) ។ កុមារទាំងអស់សុទ្ធតែទទួលនិស្ស័យអាក្រក់មកពីអាដាមតាំងពីកំណើត : *« តាមរយៈមនុស្សតែម្នាក់ បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ ។ ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ។ ... សរុបមក ដោយសារកំហុសរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ត្រូវជាប់ទោសយ៉ាងណា ដោយសារអំពើសុចរិតរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ក៏បានសុចរិត និង បានទទួលជីវិតយ៉ាងនោះដែរ »* (រ៉ូម ៥:១២, ១៨) ។

ដូច្នេះ យើងឃើញថា កុមារម្នាក់ៗមាននិស្ស័យជាមនុស្សបាប ហើយតែងតែប្រព្រឹត្តខុសឆ្គង *“...គ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ”* (រ៉ូម ៣:២៣) ។ ហេតុនេះហើយបានជាយើងត្រូវបង្រៀនកុមារម្នាក់ៗ ឱ្យចេះលន់តួសារភាពអំពើបាបរបស់ខ្លួន កែប្រែចិត្តគំនិតដោយស្មោះត្រង់ និង ជឿលើព្រះយេស៊ូគ្រីស្ត ។



តើកុមារណាខ្លះ ដែលចាំបាច់ត្រូវទទួលការសង្គ្រោះពីព្រះយេស៊ូ ?

☐ កុមារដែលធំឡើងក្នុងគ្រួសារអ្នកមិនជឿ ដែលតែងតែខូច ។

☐ កុមារទាំងអស់ ។

- ស្តេចសេណាខេរីបឈ្លានពានមកលើស្រុកយូដា : អេសាយ ៣៦-៣៧
  (ទុកចិត្តថា ព្រះជាម្ចាស់នឹងគង់នៅជាមួយយើង ពេលមានគ្រោះថ្នាក់) ។
- ព្រះជាម្ចាស់ការពារលោកប៉ូល និង លោកស៊ីឡាស នៅក្រុង ភីលីព : កិច្ចការ ១៦:១៦-៤០
- ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ សន្យាប្រទានការសង្គ្រោះដល់អស់អ្នក ដែលជឿលើព្រះអង្គ : លូកា ២៤:៣៦-៤៩
- ព្រះជាម្ចាស់ប្រោសស្តេចអេសេខ្យាស អោយជាពីជំងឺ និងអំនួតរបស់ស្តេចនេះ : អេសាយ ៣៨-៣៩
  (ទុកចិត្តលើព្រះជាម្ចាស់ មិនមែនលើទ្រព្យសម្បត្តិទេ) ។
- អ្នកមានឆោតល្ងង់ : លូកា ១២:១៥-៣៤
- លោកយេរេមី និង ក្អមទឹកបែក : យេរេមី ១៩
  (ចៀសវាងអំពើពុតត្បុតគ្រប់យ៉ាង) ។
- ពួកអ្នកដែលថាខ្លួនមើលឃើញ ជាមនុស្សខ្វាក់ : យ៉ូហាន ៩

- លោកយ៉ូបទទួលរងទុក្ខលំបាក ដោយជំនឿ : យ៉ូប (សៀវភៅយ៉ូបទាំងមូលរៀបរាប់រឿងតែមួយ) ។ អាចនិទានរឿងដោយបញ្ជាក់ផ្នែកសំខាន់ៗរបស់ចំពូក ១-៤ និង ផ្នែកសំខាន់ៗរបស់ការសន្ទនាដូចជា : យ៉ូប ៦:១-៤, ៨:១-៨, ៩:១-៤, ១១:១-៦, ១២:១-៣, ១៩:១-៦, ២៥-២៧, ៣៨:១-៧, ៤០:១-៩, ៤២
  (ទទួលរងទុក្ខលំបាក តាមព្រះហឫទ័យព្រះជាម្ចាស់) ។
- ព្រះយេស៊ូទទួលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាព្រះអង្គ នៅក្នុងសួនកេតសេម៉ានី : ម៉ាថាយ ២៦:៣៦-៤៦
- ព្រះជាម្ចាស់បានត្រាស់ហៅលោកអេសាយឱ្យផ្សាយដំណឹងល្អ : អេសាយ ៦
  (ធ្វើតាមព្រះជាម្ចាស់ ពេលព្រះអង្គត្រាស់ហៅ) ។
- ព្រះយេស៊ូបង្គាប់ពួកសិស្សរបស់ទ្រង់ អោយបង្កើតសាវ័កនៅគ្រប់ជាតិសាសន៍ក្នុងពិភពលោក : ម៉ាថាយ ២៨:១៦-២០
- ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ត្រាស់ហៅលោកពេត្រុសអោយថែរក្សាចៀមរបស់ព្រះអង្គ : យ៉ូហាន ២១:១៥-២២

«មនុស្សគ្រប់គ្នាបានវង្វេងចេញឆ្ងាយពីព្រះជាម្ចាស់ ហើយវិនាសបាត់បង់ជាមួយគ្នា គ្មាននរណាប្រព្រឹត្តអំពើសប្បុរសសោះឡើយ សូម្បីតែម្នាក់ក៏គ្មានផង » ។

«...ជួនេះ គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ដោយការប្រព្រឹត្តតាមវិន័យនោះទេ ព្រោះវិន័យគ្រាន់តែនាំអោយគេស្គាល់អំពើបាបប៉ុណ្ណោះ » ។

(រ៉ូម ៣:១០-១២, ២០)



ដើម្បីផ្សាយដំណឹងល្អដល់កុមារម្នាក់ សេចក្តីសំខាន់បំផុត គឺ :

☐ ទិញសម្ភារៈថ្លៃៗសំរាប់ផ្សាយដំណឹងល្អ ។

☐ ផ្តល់សម្ភារៈដែលមានរូបភាពបំភ្លឺល្អ សំរាប់សាលាថ្ងៃអាទិត្យ ដល់គ្រូបង្រៀន ។

☐ ឪពុកម្តាយ ឬ មិត្តភក្តិនាំកុមារអោយទទួលជឿព្រះយេស៊ូ ។



រឿងរបស់សម្ពន្ធមេត្រីចាស់ នៅក្នុងរយៈពេលនិរទេសចេញពីស្រុក និង ការស្តារស្រុកអ៊ីស្រាអែលឡើងវិញ រួមនឹងរឿងនៃសម្ពន្ធមេត្រីថ្មីដែលទាក់ទងគ្នា និង ការអនុវត្តរឿងទាំងនោះ :

រឿង

- លោកនេហេមីកសាងក្រុងយេរូសាឡឹមឡើងវិញ : នេហេមី ១-៤
- ចៀមដែលវង្វេង : លូកា ១៥:១-៧
  (ទូលសូមអោយព្រះជាម្ចាស់កែប្រែអ្នក ដែលបែរចេញពីព្រះជាម្ចាស់ អោយងាកមកព្រះជាម្ចាស់វិញ) ។
- ព្រះជាម្ចាស់ជួយសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ តាមរយៈ
  នាងអេសធែរ : សៀវភៅទាំងមូល ជារឿងតែមួយ
  (ដឹងថា ព្រះជាម្ចាស់ជីវិសុទ្ធរបស់យើង នឹងជំនុំជំរះមនុស្ស ទាំងអស់ដោយសុចរិត) ។
- អ្នកគង្វាលល្អសន្យាថា នឹងថែរក្សាប្រជារាស្ត្ររបស់ទ្រង់ជា
  រៀងរហូត : យ៉ូហាន ១០:១-៣០

- ប្រស្នាអំពីប្រាក់ណែន : ម៉ាថាយ ២៥:១៤-៣០
- បរាជ័យរបស់ក្រុងយេសារ្សឡឹម : ២ ពង្សាវតារក្សត្រ ២៥ (ស្តាប់បង្គាប់ព្រះជាម្ចាស់ ដែលវិនិច្ឆ័យទោសគ្រប់ជាតិសាសន៍) ។
- ការជំនុំជំរះជាតិសាសន៍នានា : ម៉ាថាយ ២៥:៣១-៤៦



របៀបប្រសើរបំផុតសំរាប់នាំកុមារអោយស្គាល់ និង ដើរតាមព្រះ-អម្ចាស់យេស៊ូគ្រីស្ត គឺឪពុកម្តាយ ឬ មិត្តភក្តិត្រូវទទួលខុសត្រូវក្នុងកិច្ចការនេះ ដោយមិនត្រូវពឹងផ្អែកតែលើគ្រូបង្រៀនប៉ុណ្ណោះទេ ព្រោះគ្រូត្រូវទទួលបន្ទុកមើលកុមារច្រើននាក់ណាស់ ។



សូមសរសេរឈ្មោះរបស់កុមារជាក្លូនៗរបស់អ្នកជិតខាង ដែលចាំបាច់ត្រូវស្គាល់ព្រះគ្រីស្ត :

_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____

សូមអធិស្ឋានសំរាប់កុមារទាំងនោះ ជាប់ជាប្រចាំ ។

តើអ្នកណាអាចទទួលខុសត្រូវលើកុមារទាំងនោះ ? តើសមាជិកក្រុមជំនុំណាខ្លះ ដែលអាចនិយាយរឿងក្នុងព្រះគម្ពីរប្រាប់ក្លូនៗរបស់ខ្លួន និង កុមារផ្សេងទៀតនៅឯផ្ទះ ? សូមសរសេរឈ្មោះសមាជិកទាំងនោះ :

_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____

- លោកណាម៉ាន់បានជាពីជំងឺឃ្លង់ : ២ ពង្សាវតារក្សត្រ ៥ (ត្រូវទុកអោយព្រះជាម្ចាស់កែប្រែចិត្តគំនិតអ្នក) ។
- លោកសូលថ្វាយខ្លួននៅតាមផ្លូវ ទៅទីក្រុងដាម៉ាស : កិច្ចការ ៩
- ការកែទម្រង់របស់ស្តេចយ៉ូស្យាស ដែលជាស្តេចក្មេង : ២ ពង្សាវតារក្សត្រ ២២-២៣ (ចេះមើលស្គាល់គ្រីស្តជនក្នែងក្លាយ) ។
- ពិធីមង្គលការ : ម៉ាថាយ ២២:១-១៤
- ព្រះមហាក្សត្រីយានីស្រុកសាបា យាងមកគាល់ស្តេចសាឡូម៉ូន : ២ របាក្សត្រ ៩ (ត្រូវទទួលស្គាល់ព្រះពររបស់ព្រះជាម្ចាស់) ។
- ស្ត្រីក្រមុំដប់នាក់ និង ចង្កៀង : ម៉ាថាយ ២៥:១-១៣
- ព្យាការីមីកាទាយប្រាប់ពីបរាជ័យរបស់ស្តេចអខាប់ : ២ របាក្សត្រ ១៨
- ត្រូវប្រើសមត្ថភាព និង ទេពកោសល្យ ដែលព្រះជាម្ចាស់ប្រទានឱ្យយើង ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។

- លោកអេលីសេ និង ការអស្ចារ្យលើទឹក :
  ២ ពង្សាវតារក្សត្រ ៣
  (សរសើរតម្កើងព្រះជាម្ចាស់ ចំពោះឫទ្ធានុភាពអស្ចារ្យរបស់ព្រះអង្គ) ។
- ព្រះយេស៊ូយាងដើរលើទឹក : ម៉ាថាយ ១៤:២២-៣៣
- លោកអេលីសេ និង ការអស្ចារ្យលើប្រេង :
  ២ ពង្សាវតារក្សត្រ ៤:១-៧
  (ទូលសូមអោយព្រះម្ចាស់ជួយ និង ប្រោសអ្នកអោយជា-មានសុខភាពល្អ) ។
- ព្រះយេស៊ូប្រោសមនុស្សខ្វាក់ឈ្មោះបារទីមេអោយភ្លឺឡើងវិញ : ម៉ាកុស ១០:៤៦-៥៣
- លោកអេលីសេ និង ស្ត្រីភូមិស៊ូណែម : ២ ពង្សាវតារក្សត្រ ៤:៨-៣៧
  (ទុកចិត្តលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលប្រោសអោយមានជីវិត) ។
- លោកពេត្រុស និង នាងឌំរកាស : កិច្ចការ ៩:៣៦-៤៣

ខ្ញុំមិនចេះបង្រៀនទេ តែខ្ញុំយកខ្មៅដៃពណ៌អោយប្អូនៗខ្ញុំ និង មិត្តភក្តិរបស់ប្អូនៗខ្ញុំ គូររូបអប្រាហាំ អ៊ីសាក់ និង យ៉ាកុប ។ រួចខ្ញុំកាត់រូបទាំងនោះ មកបិទនៅទីនេះ ដើម្បីអោយខ្ញុំពុកខ្ញុំអាចនិយាយរឿងរបស់អប្រាហាំ អ៊ីសាក់ និង យ៉ាកុបប្រាប់ប្អូនៗ ។



តើអ្នកណាអាចរៀបចំសម្ភារៈសំរាប់បង្រៀន ដូចជារូបគំនូរ តុក្តតា និង ភេសជ្ជៈសំរាប់ជួយដល់គ្រូបង្រៀនកុមារ ? (កុមាររៀនឆាប់ចេះ បើសិនជាមានអ្វីមួយសំរាប់មើលផង ស្តាប់គ្រូនិយាយផង) ។ សូមសរសេរឈ្មោះអ្នកជំនួយទាំងនោះ :

_____ _____ _____
_____ _____ _____
_____ _____ _____
_____ _____ _____

© Project WorldReach © SEAN

ការផ្សាយដំណឹងល្អដល់កុមារ ប្រកបដោយប្រសិទ្ធិភាព

កុមារដែលចេះដើរតាមព្រះយេស៊ូគ្រីស្ត ដោយចិត្តស្មោះត្រង់ តែងតែបានឆ្លងកាត់សេចក្តីខាងក្រោមនេះ :

- សាច់ញាតិ ឬ មិត្តភក្តិខ្លះបានស្រឡាញ់ និង កសាងកុមារឡើង ដោយប្រៀនប្រដៅ និង ធ្វើជាគំរូតាមរបៀបគ្រីស្តជនដល់ពួកគេ ។
- កុមារនោះបានជួយក្នុងការបង្រៀនកុមារតូចៗជាងខ្លួន អោយក្លាយជាសិស្សរបស់ព្រះយេស៊ូ ។
- កុមារនោះបានទទួលការស្រឡាញ់ ការយល់ចិត្ត និង ការគាំទ្រពីសំណាក់ក្រុមជំនុំ ។
- កុមារនោះបានចូលរួមក្នុងការថ្វាយបង្គំ ឬ ថ្នាក់រៀននៅក្នុងក្រុមជំនុំ ដែលគេបង្រៀនសេចក្តីដែលកុមារអាចយល់បាន ។
- កុមារនោះបានទទួលជឿព្រះយេស៊ូគ្រីស្ត ហើយទទួលពិធីជ្រមុជទឹក ។

- លោកអេលីផ្តត់ផ្តង់ស្ត្រីមេម៉ាយ នៅសារិបតា : ១ ពង្សាវតារក្សត្រ ១៧ (ត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកអោយដូចខ្លួនអ្នក) ។
- សេចក្តីស្រឡាញ់ ដែលបង្ហាញដោយអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរស : លូកា ១០:២៥-៣៧
- ព្រះជាម្ចាស់ជុតពួកអ្នកបះបោរ : ២ ពង្សាវតារក្សត្រ ១ (កោតខ្លាចព្រះជាម្ចាស់ ដែលជាចៅក្រមធំខ្ពស់បំផុត) ។
- អេលីម៉ាសទទួលទណ្ឌកម្ម ក្លាយជាខ្វាក់ : កិច្ចការ ១៣:៤-១២
- លោកអេលីឡើងទៅស្ថានបរមសុខ លោកអេលីសេបន្តតំណែងរបស់លោកអេលី : ២ ពង្សាវតារក្សត្រ ២ (រិះគិតអំពីអ្វីៗនៅស្ថានបរមសុខ) ។
- ព្រះយេស៊ូយាងឡើងទៅលើស្ថានបរមសុខ ដោយគង់លើពពក : កិច្ចការ ១:១-១១

រឿងរបស់សម្ពន្ធមេត្រីចាស់ក្នុងព្រះគម្ពីរ នៅក្នុងរយៈពេលដែលរាជាណាចក្របាក់បែក រួមនឹងរឿងរបស់សម្ពន្ធមេត្រីថ្មី ដែលទាក់ទងគ្នា និង ការអនុវត្តរបស់រឿងទាំងនោះ :

រឿង

- ដោយសារតែស្តេចមានចិត្តកំណាញ់ ទើបរាជាណាចក្របាក់បែក : ១ ពង្សាវតារក្សត្រ ១២
  (ត្រូវប្រយ័ត្នចំពោះគ្រោះថ្នាក់ ដែលបណ្តាលមកពីទ្រព្យសម្បត្តិ) ។
- យុវជនអ្នកមានម្នាក់ដើរចេញពីព្រះយេស៊ូ : ម៉ាថាយ ១៩:១៦-៣០
- លោកអេលី និង ព្យាការីរបស់ព្រះបាល :
  ១ ពង្សាវតារក្សត្រ ១៨
  (ចៀសចេញពីសាសនាក្លែងក្លាយគ្រប់យ៉ាង) ។
- ព្រះយេស៊ូដាស់តឿន អោយប្រយ័ត្នចំពោះដំបែរបស់ពួកផារីស៊ី : ម៉ាកុស ៨:១៤-២១ (សូមប្រៀបធៀបជាមួយ ម៉ាកុស ១១:១៥-១៩)

- កុមារនោះបានទទួលការបង្ហាត់បង្រៀន អោយក្លាយជាសិស្សរបស់ព្រះយេស៊ូ ដើម្បីអោយកុមារប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ (ឧទាហរណ៍ កែប្រែចិត្តគំនិត ជឿ ទទួលពិធីជ្រមុជទឹក មានសេចក្តីស្រឡាញ់ ចូលរួមធ្វើពិធីកាច់នំប៉័ង អធិស្ឋាន ទទួលព្រះបន្ទូលព្រះជាម្ចាស់ ជាចំណីអាហារខាងព្រលឹងវិញ្ញាណ ដាក់ដង្វាយ និង បង្រៀនកុមារឯទៀតអោយក្លាយជាសិស្សរបស់ព្រះយេស៊ូ) ។
- កុមារនោះចេះទន្ទេញវគ្គ ឬ ខព្រះគម្ពីរខ្លះអោយចាំ ។

នៅក្នុងចំណោមសេចក្តីខាងក្រោមនេះ សូមគូសពីក្រោមសេចក្តីប្រាំបួនយ៉ាង ដែលជួយកុមារខ្លាំងជាងគេអោយស្គាល់ និង ដើរតាមព្រះយេស៊ូ ។

ក) មាននរណាម្នាក់ ដែលបានអធិស្ឋានសំរាប់កុមារជាញឹក-ញាប់ ។

ខ) ឪពុកម្តាយបង្រៀនកុមារ និង ធ្វើជាគំរូល្អសំរាប់កុមារ ។

គ) កុមារទន្ទេញ និង ចាំខសំខាន់ៗរបស់ព្រះគម្ពីរ ។

ឃ) កុមាររៀនជាមួយគ្រូបង្រៀន ដែលមានសញ្ញាបត្រ ។

ង) កុមាររៀនអោយចេះអធិស្ឋាន ដាក់ដង្វាយ និង ចូលរួមធ្វើពិធីកាច់នំប៉័ង ។

ច) កុមារបង្រៀនកុមារតូចៗឯទៀត ឱ្យក្លាយទៅជាសិស្សរបស់ព្រះយេស៊ូ ។

ឆ) កុមារចូលរួមក្នុងការប្រជុំនៅក្នុងសាលធំទូលាយ មានខ្យល់ចេញចូលល្អ ។

ជ) មនុស្សខ្លះស្រឡាញ់កុមារ ហើយជួបជាមួយកុមាររាល់អាទិត្យ ឬ ពីរអាទិត្យម្តង ដើម្បីបង្រៀនគេអោយក្លាយជាសិស្សរបស់ព្រះយេស៊ូ ។

ឈ) កុមារដឹងថា មានមនុស្សស្រឡាញ់គេ នៅពេលដែលគេទៅព្រះវិហារ ។

ញ) កុមារទន្ទេញចាំឈ្មោះស្តេចទាំងអស់ក្នុងព្រះគម្ពីរ ។

ដ) កុមារយល់ពីសេចក្តីដែលគេរៀន និង ធ្វើតាមសេចក្តីដែលគេបានរៀននោះ ក្នុងជីវិតរបស់គេផ្ទាល់ ។

- ព្រះយេស៊ូយាងចូលទៅក្រុងយេរូសាឡឹម ក្នុងឋានៈជាស្តេច : លូកា ១៩:២៨-៤៤
- ស្តេចដាវីឌប្រណីសន្តោសដល់ម៉េភីបូសែត : ២ សាមូអែល ៩ (ដឹងព្រះគុណចំពោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ចំពោះយើង ដែលយើងមិនសមនឹងទទួល) ។
- ប្រាក់ឈ្នួលកម្មករ : ម៉ាថាយ ២០:១-១៦
- អាប់សាឡុមបះបោរប្រឆាំងនឹងស្តេចដាវីឌ : ២ សាមូអែល ១៥-១៩ (មានភាពស្មោះត្រង់តែចំពោះស្តេចប៉ុណ្ណោះ) ។
- កម្មករទុច្ចរិត : ម៉ាថាយ ២១:៣៣-៤៦
- ស្តេចសាឡូម៉ូនទូលសុំប្រាជ្ញា : ១ ពង្សាវតារក្សត្រ ៣-៤ (ត្រូវស្វែងរកប្រាជ្ញាពិត) ។
- ព្រះយេស៊ូជាផ្លូវ ជាសេចក្តីពិត : យ៉ូហាន ១៤:១-១០

- យ៉ូណាថានជួយដាវីឌអោយគេចខ្លួន ១ សាមូអែល ១៩:
  ១-៥ និង ២០
  (ត្រូវជួយមិត្តភក្តិអ្នកទាំងអស់អោយបានសង្គ្រោះ) ។
- ព្រះយេស៊ូប្រទានអោយស្ត្រីសាសន៍សាម៉ារីបានសង្គ្រោះ :
  យ៉ូហាន ៤
- ដាវីឌមិនដាច់ចិត្តធ្វើគុតស្តេចសាអ៊ូល : ១ សាមូអែល ២៤
  (ត្រូវអត់ទោសអោយសត្រូវរបស់អ្នកដែរ) ។
- ឪពុកអត់ទោសអោយកូន : លូកា ១៥:១១-៣១
- ស្តេចសាអ៊ូលទៅរកគ្រូធ្មប់ : ១ សាមូអែល ២៨
  (ចៀសអោយឆ្ងាយពីសកម្មភាពអបិយ៍ជំនឿ និង ទំនាក់ទំនង
  គ្រប់យ៉ាងជាមួយអបិយ៍ជំនឿ) ។
- ក្បួនតម្រាអបិយ៍ជំនឿ ត្រូវគេដុតចោល : កិច្ចការ
  ១៩:១៧-២០
- ស្តេចដាវីឌនាំហិបនៃសម្ពន្ធមេត្រី ទៅទីក្រុងយេរូសាឡឹម :
  ២ សាមូអែល ៦-៧
  (ទទួល និង ស្តាប់បង្គាប់ព្រះយេស៊ូទុកដូចជាស្តេច) ។

ឋ) កុមារបានកែប្រែចិត្តគំនិត និង ទទួលការលើកលែងទោសពី
ព្រះជាម្ចាស់ ព្រមទាំងទទួលពិធីជ្រមុជទឹកផងដែរ ។

ចំលើយ : អ្នកត្រូវគូសពីក្រោមសេចក្តីទាំងអស់ខាងលើនេះ
លើកលែងតែសេចក្តីដែលនិយាយអំពី « គ្រូបង្រៀន ដែលមាន
សញ្ញាបត្រ » និង « សាលធំទូលាយ មានខ្យល់ចេញចូលល្អ »
និង « ទន្មេញចាំឈ្មោះស្តេចទាំងអស់ក្នុងព្រះគម្ពីរ » ។

នៅចំពោះព្រះជាម្ចាស់ តើអ្នកណាត្រូវទទួលខុសត្រូវផ្សាយដំណឹង
ល្អដល់កុមារ ? (សូមមើលអេភេសូ ៦:៤) ។

☐ ក្រុមជំនុំ ។

☐ ឪពុកម្តាយ ។

ឪពុកម្តាយត្រូវនាំកូនៗអោយថ្វាយខ្លួនទៅព្រះគ្រីស្ត ហើយបណ្តុះ
បណ្តាលកូនៗអោយរីកចំរើនឡើងក្នុងជំនឿ (មើលទុតិយកថា ៦:
៤-៩ និង យ៉ូស្វ៊ូអា ២៤:១៥) ។ ប៉ុន្តែ ឪពុកម្តាយខ្លះមិនបានធ្វើ
ដូចនេះទេ ដូច្នេះ ក្រុមជំនុំត្រូវជួយឪពុកម្តាយទាំងនោះអោយអាច
បំពេញភារៈកិច្ចរបស់ខ្លួន ។ បើសិនជាឪពុកម្តាយមិនធ្វើកិច្ចការ
នេះទេ ក្រុមជំនុំត្រូវជួយបំពេញភារៈកិច្ចនេះ ។

ពេលដែលកុមារបានស្តាប់រឿងរបស់ព្រះគម្ពីរ អំពីព្រះយេស៊ូគ្រីស្ត កុមារនឹងស្គាល់ព្រះយេស៊ូដោយខ្លួនឯង ។ ឪពុកម្តាយ និង គ្រូបង្រៀន ត្រូវជួយកុមារអោយថ្វាយជីវិតទៅព្រះអម្ចាស់ ។ ដើម្បីអាចសំរេចគោលដៅនេះបាន យើងត្រូវជួយឪពុកម្តាយ និង គ្រូបង្រៀនដោយផ្ទាល់ អោយអាច :

១- ទូលសូមឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញអោយកុមារដឹងថា គេមានអំពើបាប ហើយបង្ហាញកុមារពីតម្លៃនៃការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូចំពោះគ្រួសារ របស់គេ និង ខ្លួនគេផ្ទាល់ ។

២- បង្ហាញប្រាប់កុមារពីមូលហេតុ ដែលនាំឱ្យគេត្រូវតែទទួលការសង្គ្រោះ (ពីព្រោះគេមានបាប រ៉ូម ៣:២៣, វិវរណៈ ២១:២៧) ។

៣- និយាយរឿងរបស់ព្រះគម្ពីរ ដើម្បីអោយកុមារគ្រប់គ្នាស្គាល់ពីបុគ្គលិកលក្ខណៈរបស់ព្រះយេស៊ូ ។ កុមារត្រូវរៀនពីកំណើតរបស់ព្រះយេស៊ូ ព្រះហឫទ័យមេត្តាករុណាដ៏អស្ចារ្យរបស់ព្រះអង្គ សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះកុមារ និង ការដែលព្រះអង្គសួប់អំពើបាបគ្រប់យ៉ាង ។

- ព្រះជាម្ចាស់បញ្ឈប់ស្តេចសាអ៊ូល : ១ សាមូអែល ១៤:២៤-៥២ និង ១៥
(ត្រូវកោតខ្លាចព្រះជាម្ចាស់ ដែលស្គាល់ចិត្តរបស់យើង) ។

  បុរសអ្នកមាន និង ឡាសារជាអ្នកក្រ : លូកា ១៦:១៩-៣១

- ព្រះជាម្ចាស់ជ្រើសរើសដាវីឌឱ្យធ្វើជាស្តេច : ១ សាមូអែល ១៦
(មិនត្រូវវិនិច្ឆ័យមនុស្ស តាមតែសំបកក្រៅទេ) ។

- ស្រងែជុះក្នុងស្រូវ : ម៉ាថាយ ១៣:២៤-៤៣

- ដាវីឌឈ្នះលើកូលីយ៉ាត : ១ សាមូអែល ១៧
(ទុកចិត្តថា ព្រះជាម្ចាស់ឈ្នះលើខ្មាំងសត្រូវ) ។

- ព្រះយេស៊ូបង្ក្រាបអំណាចអារក្ស នៅពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ : លូកា ២៤:៣៦-៥៣

- ដាវីឌរត់គេចពីស្តេចសាអ៊ូល : ១ សាមូលអែល ១៨-១៩
(ទុកចិត្តថា ព្រះជាម្ចាស់ការពារ) ។

- ព្រះយេស៊ូគេចចេញពីស្រុកណាសារ៉ែត : លូកា ៤:១៦-៣០

- ហិបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ ត្រូវពួកភីលីស្ទីន ដណ្តើមយកបាន : ១ សាមូអែល ៤:១-១០ (យល់ពីការដែលព្រះយេស៊ូបានរងទុក្ខលំបាក ដើម្បីយើង) ។
- ពួកទុច្ចរិតចាប់ព្រះយេស៊ូ : ម៉ាកុស ១៤:៤៣-៦៥, ១៥:១-៣២
- អ៊ីស្រាអែលចង់បានស្តេច ហើយលោកសាមូអែលលាប ប្រេងតែងតាំងសាអ៊ូល : ១ សាមូអែល ៨-១២

  ត្រូវដើរតាមព្រះយេស៊ូ ដែលជាព្រះអម្ចាស់ និង ស្តេចរបស់យើង ។
- លោកពេត្រុសប្រកាសថា ព្រះយេស៊ូជាព្រះមេស៊ី : ម៉ាថាយ ១៦:១៣-២០
- លោកយ៉ូណាថានធ្វើការប្រយុទ្ធ ដោយក្លាហាន : ១ សាមូអែល ១៤ (ប្រឈមមុខប្រឆាំងនឹងសត្រូវរបស់ព្រះជាម្ចាស់) ។
- សេចក្តីក្លាហានរបស់លោកស្តេផាន : កិច្ចការ ៦:៨-១៥ និង ៧

៤- និយាយរឿងអំពី «គេចាប់ព្រះយេស៊ូយកទៅឆ្កាង» «ការកាត់ទោសព្រះយេស៊ូ» «ការសុគតនៅលើឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ» និង«ការយាងឡើងទៅស្ថានបរមសុខ ដើម្បីទទួលសិរីរុងរឿងរបស់ព្រះ-យេស៊ូ» ។ អ្នកជឿពិតប្រាកដផ្សាយដំណឹងល្អពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត (រ៉ូម ១០:៩-១០) ។

៥- ជួយកុមារឱ្យចេះអធិស្ឋាន និង ថ្វាយជីវិតទៅព្រះអម្ចាស់ ។

បង្រៀនកុមារអោយក្លាយជាសិស្សរបស់ព្រះយេស៊ូ

ក្រោយពេលដែលកុមារកែប្រែចិត្តគំនិតចេញពីអំពើបាបរបស់ខ្លួន ហើយទទួលជឿលើព្រះយេស៊ូគ្រីស្ត នោះកុមារត្រូវរៀនប្រតិបត្តិតាមសេចក្តីបង្គាប់ផ្សេងៗទៀតរបស់ព្រះយេស៊ូ ។ យើងត្រូវជួយឪពុកម្តាយ ឬ នរណាម្នាក់ផ្សេងទៀត អោយបង្រៀនកុមារអំពីកិច្ចការនេះ ។ បើសិនជាឪពុកម្តាយមិនបានបង្រៀនកូនៗអោយប្រតិបត្តិតាមព្រះយេស៊ូទេ យើងអាចអោយយុវជនម្នាក់ ឬ កុមារដែលធំជាង ដែលចេះទទួលខុសត្រូវ និង មានសេចក្តីស្រឡាញ់បង្រៀនកុមារនោះអោយចេះស្តាប់បង្គាប់ព្រះគ្រីស្ត ។

ត្រូវបង្រៀនកុមារអោយ :

- ចេះអធិស្ឋានរាល់ថ្ងៃ ។
- ទទួលពិធីជ្រមុជទឹក (បើសិនជាកុមារមិនទាន់បានទទួល) ។
- ជាក់ដង្វាយតាមលទ្ធភាពរបស់គេ (កុមារអាចធ្វើកិច្ចការមួយនៅក្នុងក្រុមជំនុំ បើសិនជាគ្មានលុយជាក់ដង្វាយ) ។
- ចូលរួមធ្វើពិធីកាច់នំប៉័ង ដោយលន់តួសារភាពអំពើបាបរបស់គេ ដែលជាការមិនស្តាប់បង្គាប់ និង អំពើអាត្មានិយមរបស់ខ្លួន ហើយងាកចេញពីអំពើបាបនោះ ។
- អានព្រះគម្ពីរ និង អនុវត្តតាមព្រះគម្ពីរនៅក្នុងជីវិតខ្លួន ។

កិច្ចការខ្លះសំរាប់អស់អ្នកដែលបង្រៀនកុមារអោយក្លាយជាសិស្សរបស់ព្រះគ្រីស្ត :

- ទទួលខុសត្រូវលើការរីកចំរើនខាងព្រលឹងវិញ្ញាណរបស់កុមារ ។
- ធ្វើអោយមានទំនាក់ទំនងមេត្រីភាពជាមួយកុមារ ។

រឿងរបស់សម្ពន្ធមេត្រីចាស់ នៅក្នុងរយៈពេលដែលរាជាណាចក្រនៅរួបរួមគ្នា (ស្តេចសូល ស្តេចដាវីឌ និង ស្តេចសាឡូម៉ូន) រួមនឹងរឿងរបស់សម្ពន្ធមេត្រីថ្មី ដែលទាក់ទងគ្នា និង ការអនុវត្តរបស់រឿងទាំងនោះ :

រឿង

- នាងហាណ្ណាអធិស្ឋានសុំកូនមួយ : ១ សាមូអែល ១ និង ២:១-១១
  (អធិស្ឋានទូលសូមអ្វីមួយពីព្រះជាម្ចាស់ ដោយចិត្តបរិសុទ្ធ) ។
- ស្ត្រីសាសន៍ដទៃម្នាក់ទូលសូមដោយជំនឿ អោយព្រះយេស៊ូប្រោសកូនស្រីគាត់អោយជាសះស្បើយ : ម៉ាថាយ ១៥:២១-២៨
- ព្រះជាម្ចាស់ត្រាស់ហៅសាមូអែល : ១ សាមូអែល ៣ (ត្រូវស្តាប់បង្គាប់ ពេលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ត្រាស់ហៅយើង) ។
- ព្រះវិញ្ញាណរបស់ព្រះយេស៊ូដឹកនាំលោកប៉ូល : កិច្ចការ ១៦:៦-១៥

- ព្រះយេស៊ូប្រោសយុវជនខ្មោចចូលអោយជាសះស្បើយ : ម៉ាថាយ ១៧:១៤-២១
- លោកយែបថាសង្គ្រោះជនជាតិអ៊ីស្រាអែល ហើយក៏បាត់បង់កូនស្រីរបស់លោក : វិរបុរស ១១ (ត្រូវប្រយ័ត្នចំពោះពាក្យសន្យារបស់អ្នក) ។
- លោកពេត្រុសសន្យាថា នឹងដើរតាមព្រះយេស៊ូ តែបន្ទាប់មក លោកបដិសេធព្រះអង្គ : ម៉ាថាយ ២៦:៣១-៧៥
- លោកសាំសុនរំដោះបណ្តាជន ហើយស្លាប់ដោយសារកលល្បិចល្ងចសម្លាប់ : វិរបុរស ១៣-១៦ (ជឿថាព្រះជាម្ចាស់មានឫទ្ធានុភាពសង្គ្រោះ) ។
- ព្រះយេស៊ូសុគត និង មានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះយើងរាល់គ្នា : ម៉ាកុស ១៥-១៦
- លោកបូអូសលោះកេរ្តិ៍មរតករបស់នាងរូថ : នាងរូថ (សៀវភៅទាំងមូលជារឿងតែមួយ) ។
- ព្រះយេស៊ូសុគត ដើម្បីប្រោសលោះ : ម៉ាថាយ ២៧:៣២-៦៦

- ជួបជាមួយកុមាររាល់អាទិត្យ ឬក៏ពីរអាទិត្យម្តង ដើម្បីបង្រៀនកុមារឱ្យចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ។
- ចូលរួមធ្វើកិច្ចការបំរើព្រះជាម្ចាស់ និង សកម្មភាពកំសាន្តរបស់គ្រីស្តជន ។
- ណែនាំកុមារអោយចែកចាយទីបន្ទាល់ និង បទពិសោធន៍ផ្ទាល់ខ្លួន ក្នុងឋានៈជាគ្រីស្តជន ។
- យកពេលនៅជាមួយកុមារនៅក្នុងថ្នាក់រៀន និង នៅតាមផ្ទះ ។
- ជួយកុមារឱ្យចេះអធិស្ឋាន និង រស់នៅតាមរបៀបគ្រីស្តជន ។
- ជួយកុមារអោយចេះដោះស្រាយបញ្ហារបស់ខ្លួនគេ ។

កុមារអាចចូលរួមក្នុងការថ្វាយបង្គំជាមួយមនុស្សចាស់បាន តែកុមារចាំបាច់ត្រូវថ្វាយបង្គំជាមួយកុមារ ដែលមានភាវៈ និង វ័យរបស់ពួកគេ ។ ការប្រជុំសំរាប់កុមារអាចនឹងធ្វើនៅផ្ទះណាមួយ ឬ នៅកន្លែងថ្វាយបង្គំធម្មតា នៅថ្ងៃណាមួយក្នុងសប្តាហ៍ ។

រកគ្រូបង្រៀនល្អៗសំរាប់បង្រៀនកុមារ

ត្រូវជ្រើសរើសគ្រូបង្រៀនកុមារដែលចេះរបៀបបង្រៀន និង ចេះប្រើពាក្យសំដីទៅតាមកិរិតប្រាជ្ញារបស់កុមារជាសិស្ស អោយដឹកនាំថ្នាក់រៀនរបស់កុមារ ។ ត្រូវប្រើកូនសៀវភៅនេះ ដើម្បីណែនាំគ្រូបង្រៀនទាំងអស់នោះ ។



- ព្រះអាទិត្យនៅស្ងៀម មិនដើរទៅមុខ ហើយពួកអាម៉ូរីបរាជ័យ : យ៉ូស្វ៊ូអា ១០
(ទូលសូមអោយព្រះជាម្ចាស់ធ្វើសកម្មភាពជួយយើង) ។
- ជំនឿរបស់លោកប៉ូលសង្គ្រោះកម្មកររបស់កប៉ាល ដែលលិច : កិច្ចការ ២៧
- លោកអេហ៊ូជំរុះពួកអ៊ីស្រាអែលពីពួកម៉ូអាប់ : វិរបុរស ៣
(យើងត្រូវបែរចេញពីរូបព្រះក្លែងក្លាយគ្រប់ប្រភេទ និងទទួលព្រះបន្ទូលព្រះជាម្ចាស់) ។
- អ្នកព្រោះគ្រាប់ពូជ : ម៉ាថាយ ១៣:១-២៣
- នាងដេបូរ៉ាំរុះជនជាតិអ៊ីស្រាអែល : វិរបុរស ៤-៥
(ធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់) ។
- ស្ត្រីដែលចាក់គ្រឿងក្រអូបលាបព្រះយេស៊ូ : ម៉ាថាយ ២៦:៦-១៣
- លោកកេដូនរំដោះជនជាតិអ៊ីស្រាអែល : វិរបុរស ៦-៧
(ទុកចិត្តលើព្រះជាម្ចាស់ មិនមែនលើមនុស្ស) ។

- ព្រះយេស៊ូទទួលពិធីជ្រមុជទឹក នៅក្នុងទន្លេយ័រដាន់ : ម៉ាថាយ ៣, រ៉ូម ៦:១-៩
- ការវាយយកក្រុងយេរីខូ : យ៉ូស្វ៊ូអា ៥:១៣ និង ៦ (ប្រឈមមុខនឹងទុក្ខលំបាក ដោយជំនឿ) ។
- ព្រះយេស៊ូប្រោសលោកឡាសារអោយរស់ឡើងវិញ : យ៉ូហាន ១១
- មនុស្សទាំងអស់គ្នាបរាជ័យ ដោយសារអំពើបាបរបស់មនុស្សម្នាក់ : យ៉ូស្វ៊ូអា ៧ (លន់តួសារភាពអំពើបាបគ្រប់យ៉ាង និង បែរចេញពីអំពើបាបទាំងនោះ) ។
- លោកអណាញ៉ាស និង នាងសាភីរ៉ាស្លាប់ ព្រោះអំពើបាបរបស់ពួកគេ : កិច្ចការ ៥:១-១១
- លោកយ៉ូស្វ៊ូអារក្សាពាក្យសន្យា ដែលគាត់បានធ្វើជាមួយជនជាតិកាបូនបោកប្រាស់ : យ៉ូស្វ៊ូអា ៩ (និយាយតែការពិត ទោះបីមានរឿងអ្វីកើតឡើងក៏ដោយ) ។
- លោកពេត្រុស និង លោកយ៉ូហានផ្សាយដំណឹងល្អយ៉ាងក្លាហាន : កិច្ចការ ៣-៤

អ្នកចាស់ទុំរបស់ក្រុមជំនុំ ត្រូវជ្រើសរើសគ្រូបង្រៀន ដែលពិតជាបានទទួលព្រះគ្រីស្តជាព្រះសង្គ្រោះ និង ព្រះអម្ចាស់របស់ខ្លួន និង បានទទួលពិធីជ្រមុជទឹករួចហើយ ។ លើសពីនេះទៅទៀត ចាស់ទុំត្រូវទទួលស្គាល់គ្រូបង្រៀន ដែលចេះប្រតិបត្តិតាមព្រះអម្ចាស់គ្រប់យ៉ាង និង ដែលធ្វើជាគំរូដ៏ល្អសំរាប់អោយកុមារ ដែលជាសិស្សរបស់ខ្លួន យកតម្រាប់តាម ។



© Project WorldReach © SEAN

គ្រូបង្រៀនដែលវៃឆ្លាត នឹងអធិស្ឋានពិសេសសំរាប់កុមារម្នាក់ៗ ។ គ្រូបង្រៀនទៅសួរសុខទុក្ខកុមារដល់ផ្ទះ ដើម្បីឱ្យដឹងពីសេចក្តីត្រូវការរបស់កុមារ និង ដោះស្រាយបញ្ហាតាមគំរូនៃព្រះគម្ពីរ ។ គ្រូបង្រៀនបង្ហាញកុមារពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត តាមរយៈការរស់នៅ ទឹកមុខញញឹម ព្រមទាំងមេត្រីភាពរបស់គាត់ជាមួយអ្នកបំរើក្រុមជំនុំជាមួយគ្នា និង ជាមួយកុមារដែលគាត់បង្រៀន ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអំណោយទានខាងបង្រៀន ទៅឱ្យតែពួកអ្នក ដែលមានសេចក្តីស្រឡាញ់ចំពោះសិស្សរបស់ខ្លួនប៉ុណ្ណោះ ។ ហេតុអ្វី ? (១ កូរិនថូស ១៣:១) ។

រឿងអំពីសម័យកាលរបស់លោកយ៉ូស្វ៉ាអា និង អ៊ីរបុរស រួមនឹងរឿងរបស់សម្ពន្ធមេត្រីថ្មីដែលទាក់ទងគ្នា និង ការអនុវត្តរបស់រឿងទាំងនោះ ។

រឿង :

- ព្រះជាម្ចាស់បង្គាប់យើងអោយក្លាហាន និង យកជ័យជំនះឱ្យបាន : យ៉ូស្វ៉ាអា ១
  (បង្កើតសាវ័កថ្វាយព្រះយេស៊ូ ដោយចិត្តក្លាហាន) ។
- ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ បង្គាប់យើងអោយបង្កើតសាវ័កនៅគ្រប់ជាតិសាសន៍ : ម៉ាថាយ ២៨
- នាង៉ាហាបលាក់ពួកអ្នកស៊ើបការ : យ៉ូស្វ៉ាអា ២ និង ៦:២៤-២៥
  (ធ្វើសកម្មភាពដោយជំនឿ ដែលឥតសង្ស័យ) ។
- ដោយសារជំនឿរបស់មនុស្សខ្វិន និង មិត្តភក្តិគាត់ ទើបព្រះយេស៊ូលើកលែងទោសបាបរបស់គាត់ និង ប្រោសគាត់អោយជា : ម៉ាកុស ២:១-១២
- ការឆ្លងកាត់ទន្លេយ័រដាន់ : យ៉ូស្វ៉ាអា ៣ និង ៤
  (ដើរតាមព្រះយេស៊ូគ្រីស្តអស់ពីចិត្ត) ។

- ពស់លង្ហិន : ជំរឿនប្រជាជន ២១:៤-៩
  (ទុកចិត្តថា ព្រះយេស៊ូសង្គ្រោះ) ។
- ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់លោកនីកូដេម :
  យ៉ូហាន ៣
- សត្វលារបស់លោកបាឡាមចេះនិយាយ : ជំរឿនប្រជាជន
  ២២
  (ស្គាល់ព្រះសូរសៀងព្រះជាម្ចាស់) ។
- ព្រះយេស៊ូត្រូវគេចោទប្រកាន់ថា មានអំណាចអារក្ស :
  ម៉ាថាយ ១២:២២-៤៥
- លោកបាឡាមអោយពរពួកអ៊ីស្រាអែល : ជំរឿនប្រជាជន
  ជំពូក : ២៣-២៤
  (ទទួលស្គាល់ និង អោយពរដល់ប្រជារាស្ត្ររបស់
  ព្រះជាម្ចាស់) ។
- លោកពេត្រុសទទួលស្គាល់សាសន៍ដទៃ ជាបងប្អូនក្នុង
  ព្រះជាម្ចាស់ : កិច្ចការ ១០

កុមារតូចៗចាំបានតិចណាស់ ពីសេចក្តីដែលយើងបង្រៀនគេ ។ ប៉ុន្តែ សេចក្តីស្រឡាញ់របស់យើង នៅតែជិតជាប់នៅក្នុងចិត្តគេជានិច្ច ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។ ពេលចាប់ផ្តើមបង្រៀនដំបូង គ្រូបង្រៀនមិនទាន់មានសិស្សទេ តែគាត់អាចទៅរកសិស្សមកបង្រៀន ដើម្បីចាប់ផ្តើម ។

ថ្នាក់និមួយៗមានគ្រូបង្រៀនម្នាក់ដឹកនាំ ។ គ្រូបង្រៀនម្នាក់ៗអាចមានអ្នកជំនួយពីរ ឬ បីនាក់ដែលជួយគាត់ក្នុងកិច្ចការបំរើនេះ ។

កុមារធំៗខ្លះអាចធ្វើជាអ្នកជំនួយ ។ កុមារធំៗទាំងនោះត្រូវជួបប្រជុំជាមួយគ្រូបង្រៀនមុន ដើម្បីរៀបចំមេរៀន ។ ពួកគេអាចបង្រៀនផ្នែកណាមួយនៃមេរៀន និង ជួយកុមារខ្លះធ្វើកិច្ចការអនុវត្ត ។

គោលការណ៍សំរាប់បង្រៀនកុមារ

សូមចាំថា : គោលការណ៍ទាំងនេះ សំរាប់អោយឪពុកម្តាយ គ្រូបង្រៀន និង គ្រូជំនួយប្រតិបត្តិតាម ។

គោលការណ៍ ទី ១

បង្រៀនដោយមានគោលដៅ



គ្រូបង្រៀនអាចបង្រៀនបានល្អ លុះត្រាតែគាត់ដឹងពីសេចក្តីត្រូវការរបស់កុមារ ។

- នាងម៉ៀរីយ៉ាម និង លោកអ៊ុន ទិតៀនលោកម៉ូសេជាប្អូនប្រុស : ជំរឿនប្រជាជន ១២ (គោរពគ្រូគង្វាលរបស់យើង) ។
- ស្តេចហេរ៉ូដបៀតបៀនពួកសាវ័ក : កិច្ចការ ១២
- ពួកអ្នកស៊ើបការវិលមកពីទឹកដីសន្យា ដោយភ័យខ្លាច : ជំរឿនប្រជាជន ១៣-១៤ (ស្តាប់បង្គាប់ព្រះជាម្ចាស់ ទោះជាអ្នកឯទៀតភ័យខ្លាចក៏ដោយ) ។
- លោកប៉ូល និង លោកបារណាបាសកសាងបានក្រុមជំនុំជាច្រើន ទោះជាមានការបៀតបៀនក៏ដោយ : កិច្ចការ ១៣-១៤
- ផែនដីស្រូបពួកអ្នកបះបោរ : ជំរឿនប្រជាជន ១៦ (រក្សាការបន្ទាបខ្លួន ឯកភាព និង សេចក្តីស្រឡាញ់ក្នុងចំណោមពួកអ្នកជឿ) ។
- លោកយ៉ាកុប និង លោកយ៉ូហាន ទូលសុំជំណែងពីព្រះយេស៊ូ : ម៉ាថាយ ២០:២០-២៨

- ផ្ទះដែលគេសង់លើថ្ម : ម៉ាថាយ ៧:២៤-២៩
- គេធ្វើកូនគោមាស : សេរីភាព ៣២
  (មិនថ្វាយបង្គំព្រះក្លែងក្លាយ និង មិនប្រព្រឹត្តអំពើទុច្ចរិត) ។
- ការជំនុំជំរះដ៏ធំចុងក្រោយ : វិវរណៈ ២០:១១-១៥,
  ២១:៧-៨
- ណាដាប់ និង អប៊ីហ៊ូស្លាប់នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ :
  លេវីវិន័យ ១០
- ព្រះយេស៊ូសំអាតព្រះវិហារ : យ៉ូហាន ២:១៣-២២
  (ត្រូវគោរពកោតខ្លាចព្រះជាម្ចាស់) ។
- ព្រះជាម្ចាស់ប្រទានសត្វក្រួចជាចំណីអាហារ :
  ជំរឿនប្រជាជន ១១
  (ស្កប់ចិត្តនឹងអ្វីៗ ដែលព្រះជាម្ចាស់ប្រទានមកយើង) ។
- ព្រះយេស៊ូប្រទានចំណីអាហារដល់មនុស្សបួនពាន់នាក់ :
  ម៉ាថាយ ១៥:៣២-៣៩

គោលបំណងសំខាន់បំផុតនៃការបង្រៀនរបស់គ្រីស្តជនទាំងអស់
គឺជួយសិស្សអោយចេះស្រឡាញ់ និង ប្រតិបត្តិតាមព្រះជាម្ចាស់ :

- ទីមួយ គឺអោយគេកែប្រែចិត្តគំនិតពីអំពើបាប និង ទទួលជឿ
  ព្រះគ្រីស្តជាព្រះអម្ចាស់ ។
- ទីពីរ គឺឱ្យគេចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ
  (ម៉ាថាយ ២៨:១៩-២០) ។
- ទីបី គឺអោយគេចេះអានព្រះគម្ពីរ និង អនុវត្តតាមព្រះគម្ពីរ
  ក្នុងជីវិតរបស់គេ ។
- ទីបួន គឺអោយគើរកចំរើន និង ក្លាយជាចាស់ទុំក្នុងជំនឿ ។

គោលដៅទាំងបួននេះ ជាគោលដៅទូទៅសំរាប់មេរៀនទាំងអស់
ឯមេរៀននិមួយៗ ក៏មានគោលដៅពិសេសដែរ ។ គោលដៅ
របស់មេរៀនសំរាប់បង្រៀនកុមារ ទាក់ទងទៅនឹងសេចក្តីត្រូវការ
របស់កុមារ ។ ត្រូវថតចម្លងបញ្ជីរឿងរបស់ព្រះគម្ពីរ សំរាប់ជួន
គ្រូបង្រៀនគ្រប់គ្នា ។ គ្រូជំនួយរបស់គ្រូបង្រៀន ជួយកុមារម្នាក់ៗ
ដោយផ្ទាល់ ស្របទៅតាមសេចក្តីត្រូវការរបស់កុមារម្នាក់ៗ ។

សេចក្តីត្រូវការធម្មតារបស់កុមារ

សេចក្តីត្រូវការ កុមារដែលគ្មានមិត្តភក្តិ ។

របៀបមើលឱ្យស្គាល់ កុមារនៅម្នាក់ឯង ឬ ទើបមកព្រះវិហារជាលើកទីមួយ ។

របៀបដោះស្រាយ គ្រូជំនួយនិយាយជាមួយកុមារនោះ ហើយណែនាំអោយស្គាល់កុមារឯទៀត ។ គ្រូជំនួយប្រាប់ឱ្យកុមារឯទៀត ទទួលរាក់ទាក់កុមារនោះអោយចូលជាមួយពួកគេដែរ ។

សេចក្តីត្រូវការ កុមារជាច្រើន តែងតែមានចិត្តចង្អៀតចង្អល់ ។

របៀបមើលឱ្យស្គាល់ កុមារមិនស្រុះស្រួលជាមួយគ្នាទេ គឺគេវាយតប់គ្នា ឬមួយឪពុកម្តាយត្រូវប្រដៅគេរហូត ។

- ព្រះជាម្ចាស់ប្រទានអោយទឹកចេញពីថ្ម : សេរីភាព ១៧, ជំរឿនប្រជាជន ២០
(អរព្រះគុណចំពោះជីវិតអស់កល្ប) ។
- ព្រះយេស៊ូជាអាហារដែលផ្តល់ជីវិត : យ៉ូហាន ៦
(អរព្រះគុណចំពោះជីវិតអស់កល្ប) ។
- ព្រះយេស៊ូប្រារព្ធធ្វើពិធីកាច់នំបុ័ងជាលើកទីមួយ : លូកា ២២
- ការរៀបចំទទួលក្រិត្យវិន័យ : សេរីភាព ជំពូក ១៩
(ស្តាប់បង្គាប់ព្រះជាម្ចាស់មុនអ្វីៗទាំងអស់ ដោយសារស្រឡាញ់ព្រះអង្គ) ។
- ព្រះយេស៊ូរៀបចំប្រទេសអ៊ីស្រាអែល ដើម្បីឱ្យអ៊ីស្រាអែលអាចទទួលព្រះរាជ្យរបស់ព្រះអង្គ : ម៉ាថាយ ១០
- ព្រះជាម្ចាស់ប្រទានបទបញ្ជាទាំងដប់ប្រការ : សេរីភាព ២០ និង ២៤
(ប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះជាម្ចាស់) ។

- ព្រះយេស៊ូសុគតលើឈើឆ្កាង : ម៉ាកុស ១៥, យ៉ូហាន ១:២៩
  (ទុកចិត្តលើកូនចៀមនៃព្រះជាម្ចាស់) ។
- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ : ម៉ាថាយ ២៨
- ជុំពពក និង ជុំភ្លើង : សេរីភាព ១៣:២០-២២
  (ដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណព្រះជាម្ចាស់) ។
- ព្រះយេស៊ូត្រាស់ហៅលោកលេវី : ម៉ាកុស ២:១៣-១៧
- កូនចៅអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម : សេរីភាព ១៤
  (ទូលសូមអោយព្រះជាម្ចាស់ការពារ) ។
- ព្រះយេស៊ូធ្វើឱ្យព្យុះសមុទ្រស្ងប់ : ម៉ាថាយ ៨:២៣-២៧
- ព្រះជាម្ចាស់ប្រទាននំម៉ាណា នៅក្នុងវាលរហោស្ថាន : សេរីភាព ១៦
  (ទុកចិត្តថា ព្រះជាម្ចាស់នឹងផ្គត់ផ្គង់) ។
- ព្រះយេស៊ូប្រទានចំណីអាហារអោយមនុស្សប្រាំពាន់នាក់ : យ៉ូហាន ៦

របៀបដោះស្រាយ បង្រៀនរឿងព្រះគម្ពីរដល់ថ្នាក់ទាំងមូល អំពីសេចក្តីស្រឡាញ់ (ដូចជា នាងរ៉ូថ មេត្រីភាពរវាងស្តេចដាវីឌ និង យ៉ូណា-ថាន រវាងស្តេចដាវីឌ និង មេភីប៊ូសែត ។ល។) ។ សួរសំនួរ ហើយរៀបគំរោង អំពីកិច្ចការដែលកុមារម្នាក់ៗត្រូវធ្វើ ដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់សាច់ញាតិ មនុស្សឯទៀត និង មិត្តភក្តិរបស់គេ ។ នៅពេលដែលក្មេងណាម្នាក់ប្រតិបត្តិតាមកិច្ចការនេះ គ្រូជំនួយម្នាក់ត្រូវកត់សេចក្តីនេះ ក្នុងបញ្ជីសិស្ស ដែលមាននៅទំព័រ ទី ៣៤ ។

សេចក្តីត្រូវការ កុមារខ្លះមិនទាន់បានជឿព្រះយេស៊ូ ។

របៀបមើលឱ្យស្គាល់ ឪពុកម្តាយ សាច់ញាតិ មិត្តភក្តិ ឬ គ្រូជំនួយនិយាយជាមួយកុមារម្នាក់ៗ អំពីជំនឿរបស់គេ និង និយាយជាមួយឪពុកម្តាយរបស់កុមារដែរ ។

របៀបដោះស្រាយ បើសិនជាមានតែកុមារម្នាក់ ឬ ពីរនាក់មានសេចក្តីត្រូវការនេះ គ្រូជំនួយត្រូវផ្សាយដំណឹងល្អប្រាប់កុមារទាំងនេះ និងសាច់ញាតិរបស់ពួកគេនៅផ្ទះរបស់គេ ។ ពេលដែលកុមារម្នាក់ចាប់ផ្តើមស្គាល់ព្រះគ្រីស្ត ត្រូវកត់ហេតុការណ៍ក្នុងបញ្ជីសិស្ស ។ បើសិនជាកុមារច្រើន មិនស្គាល់ព្រះយេស៊ូ ត្រូវនិយាយអំពីការសង្គ្រោះប្រាប់ដល់គេ ។ លើសពីនេះទៅទៀត ប្រាប់រឿងស្តីអំពីព្រះយេស៊ូបន្ទាប់មក និយាយផ្ទាល់ជាមួយកុមារម្នាក់ៗ និង ឪពុកម្តាយគេផងដែរ ។ ត្រូវបង្រៀនអំពីកិច្ចការសង្គ្រោះរបស់ព្រះ-យេស៊ូ យ៉ាងតិចពីរដង ក្នុងមួយឆ្នាំ ។

សេចក្តីត្រូវការ កុមារធំៗជាច្រើននាក់មិនទាន់បានទទួលពិធីជ្រមុជទឹក ។

- ព្រះយេស៊ូស្តីបន្ទោសលោកយ៉ូហាន និង លោកយ៉ាកុបដែលមានគំនិតចង់សងសឹក : លូកា ៩:៥១-៥៦
- ព្រះជាម្ចាស់ត្រាស់ហៅលោកម៉ូសេពីអណ្តាតភ្លើង ដែលឆេះចេញពីគុម្ពបន្លា : សេរីភាព ៣-៤
  (មានចិត្តគោរពកោតខ្លាចព្រះជាម្ចាស់) ។
- សិរីរុងរឿងរបស់ព្រះយេស៊ូ : ម៉ាថាយ ១៧
- លោកម៉ូសេ និង ស្តេចផារ៉ោន : សេរីភាព ៥, ៦:២៨-៧:១៣
  (ស្វែងរកយុត្តិធម៌ ដោយក្លាហាន) ។
- មរណៈភាពរបស់លោកយ៉ូហានបាទីស្ត : ម៉ាកុស ៦
- គ្រោះកាចទាំងដប់ប្រការ : សេរីភាព ៧-១១
- ការអស្ចារ្យទីមួយរបស់ព្រះយេស៊ូ : យ៉ូហាន ២:១-១២
  (កោតខ្លាច និង ប្រតិបត្តិតាមព្រះជាម្ចាស់) ។
- ឈាមនៅលើក្របទ្វារ : សេរីភាព ១២

រឿងព្រះគម្ពីរអំពីលោកម៉ូសេ រួមនឹងរឿងរបស់សម្ពន្ធមេត្រីថ្មី ដែលទាក់ទងជាមួយគ្នា និង ការអនុវត្តរបស់រឿងទាំងនោះ :

រឿង :

- កូនចៅអ៊ីស្រាអែលរងទុក្ខលំបាក នៅប្រទេសអេស៊ីប : សេរីភាព ១ (រងទុក្ខលំបាកដោយជំនឿ) ។
- ទុក្ខលំបាករបស់លោកប៉ូល : កិច្ចការ ២១:២៦-៤០, កិច្ចការ ២២-២៣, ២ កូរិនថូស ១១:២១-៣៣
- បុត្រីស្តេចផារ៉ោនជួយសង្គ្រោះទារកម៉ូសេ : សេរីភាព ២:១-១០ (ទុកចិត្តថា ព្រះជាម្ចាស់ថែរក្សាយើង ពេលយើងមានទុក្ខ-លំបាក) ។
- ព្រះយេស៊ូប្រោសមនុស្សឃ្លង់អោយជា : ម៉ាថាយ ៨:១-៤
- លោកម៉ូសេភៀសខ្លួនចេញពីប្រទេសអេស៊ីប : សេរីភាព ២:១១-១៥ (ការគ្រប់គ្រងអារម្មណ៍ខ្លួនឯង) ។

របៀបមើលឱ្យស្គាល់ គ្រូជំនួយម្នាក់សួរកុមារ ឬ ឪពុកម្តាយ ថា គេបានទទួលពិធីជ្រមុជទឹកហើយឬនៅ ។

របៀបដោះស្រាយ និយាយរឿងព្រះគម្ពីរអំពីពិធីជ្រមុជទឹក ប្រាប់កុមារ និង ពិភាក្សាជាមួយកុមារ ។ គ្រូជំនួយរៀបចំជាមួយឪពុកម្តាយ ដើម្បីធ្វើពិធីជ្រមុជទឹកអោយកុមារ ។ ពេលគេបានទទួលពិធីជ្រមុជទឹករួច ត្រូវកត់ហេតុការណ៍នេះ ក្នុងបញ្ជីសិស្ស ។

សេចក្តីត្រូវការ កុមារដែលបានទទួលពិធីជ្រមុជទឹករួចហើយ តែមិនទាន់បានចូលរួមធ្វើពិធីកាច់នំប៉័ង ។

របៀបមើលឱ្យស្គាល់ ត្រូវសួរកុមារ ឬ ឪពុកម្តាយរបស់កុមារ ថា កុមារចូលរួមក្នុងពិធីកាច់នំប៉័ងដែរឬទេ ។

របៀបដោះស្រាយ សូមអានរឿងអំពីកូនចៀម នៅថ្ងៃបុណ្យចម្លង និង អំពីពួកអ៊ីស្រាអែលដែលចេញពីប្រទេសអេស៊ីប ហើយបង្រៀនអំពីការធ្វើពិធីកាច់នំប៉័ង ។ ត្រូវរៀបចំអោយកុមារអាចទៅចូលរួមក្នុងពិធីកាច់នំប៉័ងជាមួយឪពុកម្តាយ ។ ពេលគេបានទៅចូលរួមក្នុងពិធីកាច់នំប៉័ង ត្រូវកត់ហេតុការណ៍នេះ ក្នុងបញ្ជីសិស្ស ។

សេចក្តីត្រូវការ កុមារច្រើននាក់មិនទាន់ស្គាល់គោលជំនឿសំខាន់ៗ ។

របៀបមើលឱ្យស្គាល់ កំណត់រយៈពេលទៀងទាត់ សំរាប់សួរកុមារទាំងអស់អំពីគោលជំនឿសំខាន់ៗ ។

- លោកយ៉ូសែបបកស្រាយសុបិនពីរ : កំណើតពិភពលោក ៤០ (ទុកចិត្តលើសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់) ។
- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយបង្ហាញព្រះអង្គទ្រង់អោយនាងម៉ារីជាអ្នកស្រុកម៉ាដាឡាឃើញ : យ៉ូហាន ២០:១-១៨
- លោកយ៉ូសែបបកស្រាយសុបិនរបស់ផារ៉ោន : កំណើត-ពិភពលោក ៤១
(ទុកចិត្តថា ព្រះជាម្ចាស់ប្រទានប្រាជ្ញាអោយយើង) ។
- ការបង់សំណាញ់បានត្រីយ៉ាងច្រើនអស្ចារ្យ : លូកា ៥: ១-១១
- លោកយ៉ូសែបបានជួយសង្គ្រោះបងៗរបស់លោក : កំណើតពិភពលោក ៤២-៤៧
(អត់ទោសអោយពួកអ្នក ដែលបានធ្វើបាបយើង) ។
- អ្នកបំរើដែលមិនព្រមអត់ទោសអោយគេ : ម៉ាថាយ ១៨: ២៣-៣៥

- ពួកមនុស្សបាបបានបែរមករកព្រះជាម្ចាស់វិញ (លោកយ៉ូហានបាទីស្ត) : ម៉ាថាយ ៣
(ការត្រឡប់មកជានានឹងព្រះជាម្ចាស់ ដែលយើងបានធ្វើខុសទាស់ជាមួយព្រះអង្គ) ។
- លោកយ៉ាកុបបោកចំបាប់ជាមួយទេវទូត : កំណើតពិភពលោក ៣២:២២-៣២
(ព្យាយាមអធិស្ឋានទៅព្រះជាម្ចាស់) ។
- ស្ត្រីមេម៉ាយ និង ចៅក្រមទុច្ចរិត : លូកា ១៨:១-៨
- លោកយ៉ូសែបត្រូវបងៗគាត់យកទៅលក់ : កំណើតពិភពលោក ៣៧
(ត្រូវបែរចេញពីចិត្តលោភលន់ និង កំណាញ់គ្រប់យ៉ាង) ។
- យូដាសលក់ព្រះយេស៊ូ ដើម្បីលុយ : ម៉ាថាយ ២៦:១៤-១៦, ៤៧-៥០, ២៧:៣-១០
- លោកយ៉ូសែប និង ប្រពន្ធរបស់លោកប៉ូទីផារ : កំណើតពិភពលោក ៣៩
(កុំប្រព្រឹត្តអំពើប្រាសចាកសីលធម៌) ។
- អ្វីៗដែលនាំអោយយើងសៅហ្មង : ម៉ាថាយ ១៥:១-២០

របៀបដោះស្រាយ សូមអានវគ្គទាំងឡាយរបស់សម្ពន្ធមេត្រីចាស់ និង ថ្មីដែលទាក់ទងនឹងគោលជំនឿ ។ កុមារអាចចូលរួមសំដែងឆាកល្ខោនដែលទាក់ទងនឹងរឿងព្រះគម្ពីរ ។ ត្រូវអោយកុមារអនុវត្តគោលជំនឿ នៅក្នុងជីវិតរបស់គេ ។ នៅពេលដែលកុមារបានអនុវត្តកិច្ចការ ដែលគ្រូដាក់ឱ្យនេះ (ដូចជាទន្មេញខគម្ពីរ ។ល។) ត្រូវកត់ហេតុការណ៍នេះ នៅក្នុងបញ្ជីសិស្ស ។

នៅក្នុងបញ្ជីគោលដៅនៃការបង្រៀនកុមារ អោយក្លាយជាសិស្សរបស់ព្រះយេស៊ូ ក៏វិតយល់ដឹង និង សេចក្តីដែលកុមារអាចចែកចាយជាមួយកុមារឯទៀត អាស្រ័យទៅលើកិរិតប្រាជ្ញា និង ការរីកចំរើនខាងព្រលឹងវិញ្ញាណរបស់កុមារ ។ យើងសង្ឃឹមថា ពីមួយឆ្នាំ ទៅមួយឆ្នាំ កុមារនឹងកាន់តែមានសេចក្តីស្រឡាញ់ និង ស្គាល់ព្រះជាម្ចាស់ខ្លាំងឡើងៗ ។

សូមថតចម្លងបញ្ជីគោលដៅនៃការបង្រៀនកុមារឱ្យក្លាយជាសិស្ស
របស់ព្រះយេស៊ូ ខាងក្រោមនេះ និង ទំព័របន្តបន្ទាប់ទៅនេះ សំរាប់
កុមារម្នាក់ៗ ។ សូមគូរសញ្ញាសំគាល់សកម្មភាព ដែលកុមារបាន
ធ្វើហើយ ។

**បញ្ជីគោលដៅនៃការបង្រៀនកុមារ អោយក្លាយជាសិស្សរបស់
ព្រះយេស៊ូ**

ឈ្មោះរបស់កុមារ : _____

☐ បានទទួលព្រះគ្រីស្តជាព្រះអម្ចាស់ និង ជាព្រះអង្គសង្គ្រោះ ។

☐ លន់តួសារភាពអំពើបាបរបស់ខ្លួនទូលព្រះជាម្ចាស់ ហើយ
បែរចេញពីអំពើបាប ។

☐ ទទួលពិធីជ្រមុជទឹក ។

☐ ចូលរួមធ្វើពិធីកាច់នំបុ័ង ។

☐ អធិស្ឋានរាល់ថ្ងៃ ។

☐ បង្ហាញសេចក្តីស្រឡាញ់នៅផ្ទះ ។

- ព្រះយេស៊ូប្រោសស្ត្រីម្នាក់ ដែលពាល់ជាយព្រះពស្ត្រព្រះអង្គ
អោយបានជាសះស្បើយ : ម៉ាថាយ ៩:១៨-២៦
- លោកយ៉ាកុបសុបិនឃើញជណ្តើរមួយខ្ពស់ រហូតដល់
មេឃ : កំណើតពិភពលោក ២៨
(អធិស្ឋានដោយជំនឿដោយដឹងថា ព្រះជាម្ចាស់គង់ជាមួយ
យើង) ។
- អ្នកទារពន្ធអធិស្ឋាន : លូកា ១៨:៩-១៤
- លោកយ៉ាកុបធ្វើការ ១៤ ឆ្នាំ ដើម្បីអោយបាននាងរ៉ាជែល
ធ្វើជាភរិយា : កំណើតពិភពលោក ២៩
(ការតស៊ូព្យាយាមប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះជា-
ម្ចាស់) ។
- លោកប៉ូលតស៊ូព្យាយាមក្នុងឋានៈជាគ្រីស្តទូត : កិច្ចការ ១៤
- លោកយ៉ាកុបមកជួបនឹងអេសាវ : កំណើតពិភពលោក
៣២-៣៣
(ការស្រុះស្រួលជានានឹងមនុស្ស ដែលយើងបានធ្វើខុស
ជាមួយ) ។

- ព្រះយេស៊ូទទួលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាព្រះអង្គ ដោយបូជាជីវិតព្រះអង្គដើម្បីយើងរាល់គ្នា បន្ទាប់មក ទ្រង់ត្រូវគេធ្វើគុត : ម៉ាថាយ ២៦:៣៦-៤៦, យ៉ូហាន ១៩:១៧-២៧
- ការរកប្រពន្ធអោយអ៊ីសាក់ : កំណើតពិភពលោក ២៤ (ទុកអោយព្រះជាម្ចាស់ដឹកនាំជីវិតយើង) ។
- អ្នកនេសាទត្រីដើរតាមព្រះយេស៊ូ : ម៉ាថាយ ៤:១៨-២២
- អ៊ីសាវលក់សិទ្ធិរបស់គាត់ជាកូនច្បង : កំណើតពិភពលោក ២៥:១៤
  (ការមានចិត្តដឹងគុណចំពោះមរតក នៅស្ថានបរមសុខរបស់យើង) ។
- ហោរាចារ្យដើរកព្រះបុត្រារបស់ព្រះជាម្ចាស់ : ម៉ាថាយ ២
- លោកអ៊ីសាក់អោយពរយ៉ាកុប និង អ៊ីសាវ : កំណើត-ពិភពលោក ២៧
  (ការស្វែងរកព្រះពររបស់ព្រះជាម្ចាស់) ។

- ☐ បង្ហាញសេចក្តីស្រឡាញ់ដល់មិត្តភក្តិ ។
- ☐ ទន្ទេញខគម្ពីរសំខាន់ៗអោយចាំស្មាត់ ។
- ☐ ចេះដាក់ដង្វាយ ។
- ☐ ផ្សាយដំណឹងល្អអំពីព្រះយេស៊ូដល់មនុស្សឯទៀត ។
- ☐ ជួយបង្រៀនកុមារតូចៗឱ្យក្លាយទៅជាសិស្សរបស់ព្រះយេស៊ូ។
- ☐ អាចនិយាយពីកំណើតព្រះយេស៊ូ ។
- ☐ អាចនិយាយពីអារក្សល្បួងព្រះយេស៊ូ ។
- ☐ អាចនិយាយពីការអស្ចារ្យរបស់ព្រះយេស៊ូ ។
- ☐ អាចនិយាយពីការសុគតរបស់ព្រះយេស៊ូ ។
- ☐ អាចនិយាយពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ។
- ☐ បំពេញភារៈកិច្ចសង្គមកិច្ចរបស់ខ្លួន ។
- ☐ មានកិច្ចការបំរើមួយក្នុងក្រុមជំនុំ ។

© Project WorldReach © SEAN

អាចនិយាយប្រាប់គេអំពី :

- ☐ និស្ស័យជាមនុស្សរបស់ព្រះយេស៊ូ ។
- ☐ និស្ស័យជាព្រះរបស់ព្រះយេស៊ូ ។
- ☐ ការយាងឡើងទៅស្ថានបរមសុខរបស់ព្រះយេស៊ូ ។
- ☐ ការយាងមករបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។
- ☐ កិច្ចការរបស់ព្រះវិញ្ញាណ ។
- ☐ ព្រះឯកត្រីអង្គ ។
- ☐ ក្រុមជំនុំជាអ្វី ។
- ☐ ប្រភពនៃអំពើបាប ។

គ្រូបង្រៀនត្រូវរកជំហានបន្ទាប់ ដែលកុមារត្រូវអនុវត្ត ហើយកត់ត្រាអំពីការរីកចំរើនរបស់សិស្សម្នាក់ៗនៅក្នុងបញ្ជីសិស្ស ។ ដោយប្រើបញ្ជីនេះ គ្រូបង្រៀនអាចវាស់ដឹងពីភាពនៃការរីកចំរើនរបស់កុមារម្នាក់ៗ ដោយសារការអនុវត្ត ដែលកុមារបានធ្វើ ហើយអាចដឹងថា កុមារចេះប្រតិបត្តិតាមសេចក្តីបង្គាប់ណាខ្លះរបស់ព្រះយេស៊ូ ។ ម៉្យាងទៀត គ្រូបង្រៀនអាចដឹងពីកិច្ចការដែលកុមារចាំបាច់ត្រូវធ្វើបន្តទៀត ។ បើធ្វើរបៀបនេះ យើងអាចនឹងរៀបចំមេរៀនដែលត្រូវនឹងសេចក្តីត្រូវការរបស់កុមារម្នាក់ៗ ។

- ព្រះជាម្ចាស់សន្យាប្រទានបុត្រាអោយនាងម៉ារី : លូកា ១:២៦-៥៦
- លោកអប្រាហាំទូលអង្វរសំរាប់ទីក្រុងសូដុម : កំណើត-ពិភពលោក ១៨:១៦-៣៣ (អធិស្ឋានអោយអ្នកដែលបាត់បង់) ។
- អ្នកគង្វាលដ៏ល្អស្វែងរកចៀម ដែលវង្វេង : លូកា ១៥: ១-៧
- ព្រះយេស៊ូទូលអង្វរឱ្យអស់អ្នកជឿលើព្រះអង្គ : យ៉ូហាន ១៧
- កំណើតកូនប្រុសដែលព្រះជាម្ចាស់សន្យា : កំណើតពិភព-លោក ២១ (ការជឿលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់) ។
- កំណើតរបស់ព្រះយេស៊ូ : ម៉ាថាយ ១
- ព្រះជាម្ចាស់ល្បងលជំនឿរបស់លោកអប្រាហាំ : កំណើត-ពិភពលោក ២២ (ការប្រតិបត្តិតាមព្រះជាម្ចាស់ មុនអ្វីៗទាំងអស់) ។

© Project WorldReach © SEAN

- លោកពេត្រុស និង លោកយ៉ូហានជាប់ក្នុងមន្ទីរឃុំឃាំង : កិច្ចការ ៤
- អ្នកឃ្វាលសត្វរបស់លោកអប្រាហាំ និង លោកឡុតឈ្លោះគ្នា : កំណើតពិភពលោក ១៣ (ត្រូវលះបង់ចោលភាពអាត្មានិយម) ។
- អ្នកបំរើស្មោះត្រង់ និង អ្នកបំរើមិនស្មោះត្រង់ : លូកា ១២:៤១-៤៨
- ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ចំពោះលោកអប្រាហាំ : កំណើតពិភពលោក ១៥ (ការរស់ដោយមានជំនឿលើព្រះជាម្ចាស់) ។
- ព្រះយេស៊ូប្រោសបុរសខ្វាក់ពីរនាក់ អោយភ្លឺឡើងវិញ : ម៉ាថាយ ៩:២៧-៣១
- គេមើលស្គាល់ព្រះគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ នៅភូមិអេម៉ាអ៊ូស : លូកា ២៤:១៣-៣៥
- ព្រះជាម្ចាស់សន្យាប្រទានកូនប្រុសម្នាក់ឱ្យលោកអប្រាហាំ : កំណើតពិភពលោក ១៨ (ទីពឹងលើព្រះបន្ទូលព្រះជាម្ចាស់ ដោយជំនឿ) ។

កំណត់ចំណាំ : សំរាប់គ្រូបង្រៀនថ្នាក់កុមារធំៗ អ្នកអាចថតចម្លងគោលដៅនៃការបង្កើតសាវ័ករបស់កូនសៀវភៅ ទី ៦១ «កម្មវិធីសំរាប់បង្រៀនក្រុមជំនុំរបស់អ្នក» ។



យើងបង្រៀនកុមារតម្រូវទៅតាមសេចក្តីត្រូវការរបស់កុមារ ។ បើសិនជាកុមារជាអ្នកជឿ ដែលទទួលពិធីជ្រមុជទឹកហើយ នោះយើងមិនអាចជួយកុមារនោះ ដោយគ្រាន់តែនិយាយដដែលៗ ពីគោលជំនឿស្តីពីការសង្គ្រោះប៉ុណ្ណោះទេ ។ តើយើងត្រូវជួយកុមារអោយធ្វើកិច្ចការអ្វី ? សូមរកចំលើយនៅក្នុង ហេប្រឺ ៦:១-២ និង ម៉ាថាយ ២៨:១៨-២០ ។

បើសិនជាកុមារមិនទាន់ជឿ ឬ ទើបនឹងជឿថ្មី យើងមិនត្រូវបង្រៀនកុមារនោះពីគោលជំនឿពិបាកៗទេ ។ ព្រោះអ្វី ? ។

យើងបង្រៀនកុមារ ដែលមិនទាន់ជឿដំណឹងល្អព្រះយេស៊ូ គឺបង្រៀនអំពីសេចក្តីស្រឡាញ់ និង ភាពបរិសុទ្ធរបស់ព្រះពិតតែមួយ ដែលដាក់ទោសមនុស្សប្រព្រឹត្តអំពើបាបគ្រប់យ៉ាងទាំងអស់ អំពីការសុគត និង ការរស់ឡើងវិញរបស់ព្រះគ្រីស្ត និង អំពីការលើកលែងទោសដ៏នៅអស់កល្បរបស់ព្រះជាម្ចាស់ ដោយសារព្រះយេស៊ូផង ។ យើងអញ្ជើញពួកគេអោយកែប្រែចិត្តគំនិត និង ជឿលើព្រះគ្រីស្ត ។

- ព្រះយេស៊ូ និង ស្ត្រីសាសន៍សាម៉ារី : យ៉ូហាន ៤
- លោកណូអេ និង ទូកធំ : កំណើតពិភពលោក ៦-៩ (យើងត្រូវកែប្រែចិត្តគំនិតចេញពីអំពើបាបរបស់យើង) ។
- កូនពៅដែលវង្វេងបាត់ : លូកា ១៥ (ការកែប្រែចិត្តគំនិត និង ការវិលមករកព្រះជាម្ចាស់វិញ) ។
- ប៉មបាបិល : កំណើតពិភពលោក ១១ (ទុកចិត្តលើព្រះជាម្ចាស់ មិនមែនលើអំណាចរបស់មនុស្សទេ) ។
- ការយាងមករបស់ព្រះវិញ្ញាណដ៏វិសុទ្ធ : កិច្ចការ ២
- លោកអប្រាហាំធ្វើតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ : កំណើតពិភពលោក ១២ (ជំនឿបង្ហាញចេញជាសកម្មភាព) ។
- ព្រះយេស៊ូប្រោសអ្នកបំរើរបស់នាយទាហានដែលជឿ អោយជាសះស្បើយ : ម៉ាថាយ ៨
- លោកអប្រាហាំរំដោះលោកឡុត : កំណើតពិភពលោក ១៤ (ត្រូវអង់អាចក្លាហាន ពេលត្រូវប្រឈមមុខនឹងមនុស្សអាក្រក់) ។

រឿងរបស់ព្រះគម្ពីរសំរាប់កុមារ

រឿងរបស់ព្រីទ្ធាចារ្យក្នុងសម្ពន្ធមេត្រីចាស់ រួមនឹងរឿងរបស់សម្ពន្ធមេត្រីថ្មី ដែលទាក់ទងគ្នា និង ការអនុវត្តរបស់រឿងទាំងនោះ :

រឿង

- ការបង្កើត : កំណើតពិភពលោក ១-២ (អរព្រះគុណព្រះជាម្ចាស់ចំពោះអ្វីៗ ដែលព្រះអង្គបានបង្កើត) ។
- ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ : ម៉ាថាយ ២៨ (អរព្រះគុណចំពោះ ថ្ងៃដែលនឹងមានផ្ទៃមេឃថ្មី និង ផែនដីថ្មី) ។
- អាដាម និង នាងអេវ៉ា : កំណើតពិភពលោក ៣ (ប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីប្រឆាំងនឹងការល្បួង) ។
- ព្រះយេស៊ូឈ្នះការល្បួង : ម៉ាថាយ ៤
- លោកកាអ៊ីន និង លោកអេបិល : កំណើតពិភពលោក ៤ (ថ្វាយបង្គំ ដោយចិត្តបរិសុទ្ធ) ។

កុមារក៏ដូចជាមនុស្សពេញវ័យដែរ គឺគេមិនអាចយល់ពីសេចក្តីខាងព្រលឹងវិញ្ញាណទេ ទាល់តែគេបានស្គាល់ព្រះយេស៊ូជាព្រះសង្គ្រោះ និង ព្រះអម្ចាស់របស់ខ្លួនហើយ ទើបគេអាចយល់បាន ។ ព្រោះអ្វី ? (សូមមើល ១ កូរិនថូស ២:៩-១៦) ។

_____

_____

ការសិក្សាអាចជួយកសាងកុមារបាន លុះត្រាតែយើងធ្វើអោយការសិក្សានោះ ទាក់ទងនឹងសេចក្តីត្រូវការរបស់កុមារ ទោះជាសេចក្តីត្រូវការអ្វីក៏ដោយ ។

គោលការណ៍ ទី ២

រៀបចំមេរៀនអោយបានល្អ មុនពេលត្រូវបង្រៀន

យើងរៀបចំដើម្បីជួយកុមារផ្ទាល់ អោយចេះដោះស្រាយបញ្ហា និង សេចក្តីត្រូវការរបស់ខ្លួនគេ ។



- រៀបចំផែនការសំរាប់ធ្វើកម្មវិធីពិសេសៗប្រចាំឆ្នាំ (ដូចជា : បុណ្យកំណើតព្រះយេស៊ូ បុណ្យរំលឹកពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ បុណ្យអុំទូក...។ល។) ។
- ជួយគ្រូបង្រៀនអោយចេះហាត់រៀន អំពីរបៀបនិទានរឿងព្រះគម្ពីរ និង អំពីរបៀបបង្រៀនកុមារអោយចេះយកសេចក្តីដែលគេបានរៀនពីព្រះគម្ពីរ ទៅអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។ អ្នកអាចប្រើបញ្ជីរឿងនៃព្រះគម្ពីរ ដើម្បីអាចនិទានរឿងផ្សេងៗរៀងរាល់អាទិត្យ ។
- ជូនបញ្ជីរឿងរបស់ព្រះគម្ពីរទៅឪពុកម្តាយ ដើម្បីអោយឪពុកម្តាយអាចបង្រៀនកូនៗ ។

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ចាប់ផ្តើមបង្ហាត់បង្រៀនឪពុកម្តាយ និង អ្នកដែលចេះទទួលខុសត្រូវឯទៀត គឺបុរស ស្ត្រី យុវជន និង កុមារធំៗឱ្យចេះបង្រៀនកុមារឱ្យក្លាយជាសិស្ស ដែលចេះប្រតិបត្តិតាមព្រះ-គ្រីស្ត ។ សូមប្រើការសិក្សានេះ ដើម្បីបង្ហាត់បង្រៀនអ្នកទាំងនោះ ។

- សរសេរផែនការអំពីការផ្សាយដំណឹងល្អ ប្រាប់កុមារឯទៀតនៅក្នុងសង្កាត់របស់ក្រុមជំនុំ (មិនមែនតែនៅថ្ងៃអាទិត្យ នៅព្រះវិហារទេ តែនៅតាមផ្ទះរបស់ពួកគេ ក្នុងរយៈពេលមួយសប្តាហ៍ៗ) :

_____

_____

_____

_____

_____

_____

_____

គ្រូបង្រៀនល្អ ចាប់ផ្តើមរៀបចំមេរៀនយ៉ាងតិចមួយអាទិត្យមុន ។ បើរង់ចាំនាទីចុងក្រោយ ទើបរៀបចំនោះ គឺមើលស្រាលការបង្រៀនព្រះគម្ពីរដល់កុមារហើយ ។ ព្រះជាម្ចាស់តម្រូវអោយគ្រូបង្រៀនរៀបចំអោយបានល្អ (១ ធីម៉ូថេ ៤:១៣ និង ២ ធីម៉ូថេ ២:១៥) ។ ដំបូងត្រូវអធិស្ឋានសិន រួចអានវគ្គគម្ពីរដែលត្រូវបង្រៀនដោយហ្មត់ចត់ ។ បន្ទាប់មក រៀបចំមេរៀនដែលធ្វើឱ្យព្រះបន្ទូលទាក់ទងទៅនឹងសេចក្តីត្រូវការរបស់កុមារ ។

គ្រូបង្រៀនត្រូវជ្រើសយករបៀបបង្រៀន ដែលល្អជាងគេសំរាប់បង្រៀនប្រធានបទនិមួយៗ ដូចជានិយាយរឿង សួរសំនួរ ដឹកនាំការពិភាក្សា ចេញទៅដើរលេង បកស្រាយអំពីអ្វីៗ ដែលអាចមើលឃើញនៅខាងក្រៅ និង ប្រើសម្ភារៈ ឬ ធ្វើសកម្មភាពដូចជា :

- រូបភាព ។
- ក្តារខៀន ។
- របស់របរសំរាប់លើកបង្ហាញជាឧទាហរណ៍បំភ្លឺមេរៀន ។
- រឿងល្ខោនខ្លីៗ ។

- រូបភាពក្រណាត់ដែលបិតលើផ្ទាំងក្រណាត់ ។
- កំណាព្យមានរូបភាពបំភ្លឺ ។
- ល្បែងកំសាន្ត ។
- ការធ្វើកាយវិការ ។
- ។ល។ ។

សេចក្តីសំខាន់ : យើងចាំបាន ១0% នៃសេចក្តីដែលយើងបានឮ ៥0% នៃសេចក្តីដែលយើងបានឃើញ និង ៨0% នៃសេចក្តីដែលយើងបានធ្វើ ។

តើគ្រូបង្រៀនត្រូវចាប់ផ្តើមរៀបចំមេរៀនសំរាប់បង្រៀន នៅពេលណា ? ។_____

ដាស់តឿនជំរុញអោយគ្រូបង្រៀនចាប់ផ្តើមរៀបចំមេរៀនយ៉ាងតិចមួយអាទិត្យមុន ។ ការអធិស្ឋានអោយកុមារម្នាក់ៗ និង សេចក្តីត្រូវការរបស់គេ គឺជាកិច្ចការសំខាន់មួយទៀតនៃការរៀបចំ ។

កុមារអំពីសេចក្តីសំខាន់ៗ ដែលទាក់ទងនឹងព្រះជាម្ចាស់ តាមរយៈជីវិត បទពិសោធន៍ និង ទំនាក់ទំនងរបស់មនុស្សជាមួយព្រះជាម្ចាស់ ។ ព្រះគម្ពីរសម្ពន្ធមេត្រីថ្មីពន្យល់ពីសេចក្តីសំខាន់ៗទាំងនោះតាមរយៈសេចក្តីបង្រៀនរបស់ព្រះយេស៊ូ កិច្ចការរបស់ពួកសាវ័ក និង លិខិតដែលពួកសាវ័កសរសេរផ្ញើទៅកាន់អ្នកជឿ ។ ខ្លឹមសាររបស់សម្ពន្ធមេត្រីថ្មី ទាក់ទងនឹងខ្លឹមសាររបស់ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ។ ដូច្នេះ គ្រូបង្រៀនត្រូវបង្រៀនមេរៀន ដែលដកស្រង់ចេញពីសម្ពន្ធមេត្រីចាស់ ឆ្លាស់ជាមួយនឹងមេរៀន ដែលដកស្រង់ចេញពីសម្ពន្ធមេត្រីថ្មី (គឺមួយអាទិត្យ បង្រៀនមេរៀនដែលដកស្រង់ពីព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ហើយសប្តាហ៍បន្ទាប់បង្រៀនមេរៀនដែលដកស្រង់ពីសម្ពន្ធមេត្រីថ្មី) ។

ហាត់និទានរឿង ដើម្បីអាចនិទានអោយបានល្អ ។

ត្រូវហាត់អាន និង និទានរឿងមួយឱ្យបានច្រើងដង មុននឹងយកទៅនិទានប្រាប់កុមារ ។ បើគ្រូបានហាត់និទានរឿងផ្សេងៗច្រើនដង ក្នុងរយៈពេលយូរនោះ គ្រូនឹងអាចនិទានរឿងទាំងនោះ ដោយស្រួល ។

© Project WorldReach © SEAN

គោលការណ៍ ទី ៨

និទានរឿងតាមរបៀបដែលអប់រំកុមារ

និទានរឿង ជាពិសេសរឿងអំពីការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ អោយបានច្រើនដងក្នុងមួយឆ្នាំ ។

កំណត់ពេល សំរាប់កុមារស្តាប់គេនិទានរឿង តម្រូវទៅតាមវ័យ និង ការរីកចំរើនរបស់កុមារ ។ មានរឿងខ្លះវែងរហូតដល់ច្រើនជំពូកក្នុងព្រះគម្ពីរ ។ ចំពោះរឿងដូចនេះ ត្រូវជ្រើសយកតែផ្នែកសំខាន់ៗជាងគេប៉ុណ្ណោះមកនិទាន ។ ឧទាហរណ៍ រឿងរបស់លោកណូអេ នៅក្នុងក័ណ្ឌគម្ពីរកំណើតពិភពលោក ចាប់ផ្តើមពីជំពូកទីប្រាំមួយដល់ជំពូកទីប្រាំបួន ។ ដូច្នេះ ត្រូវអានរឿងនេះច្រើនដង ដើម្បីជ្រើសយកផ្នែកដែលត្រូវនិទានប្រាប់កុមារ ។ សំរាប់កុមារតូចៗ ត្រូវនិទានតែបី ឬ បួនចំណុចខ្លីៗបានហើយ ។

ត្រូវបញ្ចូលរឿងរបស់សម្ពន្ធមេត្រីចាស់ និង សម្ពន្ធមេត្រីថ្មីជាមួយគ្នា ។

គ្រូបង្រៀនត្រូវនិទានរឿង ដែលដកស្រង់ចេញពីសម្ពន្ធមេត្រីចាស់ និង សម្ពន្ធមេត្រីថ្មី ។ ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ពន្យល់បំភ្លឺដល់

យើងទូលសូមអោយព្រះជាម្ចាស់ប្រទានប្រាជ្ញា ដើម្បីអាចជួយកុមារឱ្យទទួលព្រះយេស៊ូគ្រីស្ត ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ និង ស្រឡាញ់ក្រុមគ្រួសារ និង មិត្តភក្តិរបស់គេដែលរៀនជាមួយគ្នា ។

ដើម្បីរៀបចំមេរៀន គ្រូបង្រៀនត្រូវធ្វើតាមជំហានទាំងបីនេះ :

១- អធិស្ឋាន និង សិក្សាវគ្គគម្ពីរ ដែលទាក់ទងនឹងសេចក្តីត្រូវការ និង ជីវិតរបស់កុមារ ។

២- ជ្រើសរើស និង រៀបចំរបៀបបង្រៀន (ដូចជា និទានរឿង លេងតន្ត្រី បង្ហាញរូបភាពបំភ្លឺ ។ល។) ។

៣- រិះរករបៀបពិនិត្យមើលថា តើកុមារបានធ្វើលំហាត់ និង កិច្ចការ ដែលត្រូវអនុវត្ត ឬ មិនធ្វើ ។

មុនពេលបង្រៀន គ្រូបង្រៀនត្រូវរៀបចំបន្ទប់ និង ប្រមូលសម្ភារៈដែលគាត់ត្រូវការសំរាប់បង្រៀន (សៀវភៅកំណត់ហេតុ ព្រះគម្ពីរ ខ្មៅដៃ កន្ត្រែ ។ល។) ។

គោលការណ៍ ទី ៣

បង្រៀនមេរៀនអោយច្បាស់លាស់ និង ដោយទឹកចិត្តពុះកញ្ជ្រោល

យើងបង្រៀនតាមរបៀបមួយ ដែលច្បាស់លាស់ និង ខ្លី ហើយ តាមរបៀបដែលលើកទឹកចិត្តកុមារ ។



ពេលបង្រៀន គ្រូបង្រៀនមិនត្រូវអានមេរៀនរបស់ខ្លួនទេ ។ បើគ្រូបង្រៀនអានមេរៀន នោះកុមារប្រាកដជាអផ្សុក ហើយមិនយកចិត្តទុកដាក់ស្តាប់ទេ ។ នៅពេលរៀបចំមេរៀន គ្រូបង្រៀនត្រូវសរសេរតែចំណុចសំខាន់ៗរបស់មេរៀនបានហើយ ។ បើធ្វើដូច្នេះ គ្រូអាចនឹងបង្រៀនកុមារ ដោយនិយាយសេចក្តីដែលចេញពីចិត្ត គាត់ និង អាចសំលឹងមើលភ្នែករបស់កុមារផង ។

សូមគូសពីក្រោមវិធី ដែលមានប្រសិទ្ធិភាព សំរាប់បង្រៀនកុមារ ដែលអាយុពី ១០ ឆ្នាំ ទៅជំទង់ :

ក- ប្រើសូរសម្លេង ពេលអ្នកបង្រៀន ។

ខ- អោយសិស្សសំដែងរឿង ដែលទាក់ទងនឹងព្រះគម្ពីរ ។

គ- អោយសិស្សទាំងនេះ និទានរឿងអោយកុមារតូចៗស្តាប់ ឬ សំដែងល្ខោនអោយកុមារតូចៗមើល ។

ឃ- បើសិនជាអាចធ្វើបាន គ្រូវបង្រៀនកុមារាកុមារីក្នុងក្រុមផ្សេងគ្នា ។

ង- អោយសិស្សទាំងនេះគូររូបភាព និង ធ្វើកូនរូបសំរាប់អោយគ្រូៗយកទៅប្រើ នៅពេលបង្រៀនកុមារតូចៗ ។

ច- អោយសិស្សទាំងនេះធ្វើតុក្កតា និង ប្រើតុក្កតាទាំងនេះ ។

ឆ- អោយសិស្សទាំងនេះប្រៀនប្រដៅកុមារតូចៗ នៅពេលដែលកុមារតូចៗធ្វើអ្វីមិនសមរម្យ ។

ចំលើយត្រឹមត្រូវ គឺ : ខ គ ឃ ង និង ច ។

© Project WorldReach © SEAN

គ្រូបង្រៀនត្រូវដឹកនាំកុមារទាំងនេះ អោយចេះពិភាក្សា និង អោយធ្វើលំហាត់ ។ កុមារអាយុប៉ុននេះ ចូលចិត្តអាន សរសេរ និង បញ្ចេញគំនិតរបស់ខ្លួន ។ ឧទាហរណ៍ : ដឹកនាំកុមារឱ្យពិភាក្សាដោយសួរសំណួរទាំងនេះ : *«តើអ្នកគិតថា ហេតុអ្វីបានជាលោកពេត្រុសបដិសេធបីដងថា មិនស្គាល់ព្រះយេស៊ូ ? តើគាត់ខ្លាចអ្វី ? តើអ្នកគិតថា នៅពេលដែលលោកពេត្រុសបដិសេធព្រះអង្គ ព្រះយេស៊ូមានអារម្មណ៍យ៉ាងដូចម្តេច ? បើអ្នកជាលោកពេត្រុស តើអ្នកបដិសេធព្រះអង្គដែរឬទេ ? ហេតុអ្វី ? តើដែលមានមិត្តភក្តិណាសួរអ្នកថា អ្នកជាគ្រីស្តជនមែនឬទេ ? តើអ្នកឆ្លើយប្រាប់គេថាដូចម្តេច ?»* ។ បើអ្នកសួរសំណួរដូចនេះ អ្នកអាចនាំកុមារអោយពិភាក្សាគ្នា ។

ការមើលភ្នែកកុមារ មានប្រយោជន៍ច្រើនណាស់ ។ បើគ្រូបង្រៀនសំលឹងមើលកុមារនោះ កុមារនឹងខំប្រឹងស្តាប់ ហើយគ្រូបង្រៀនអាចសង្កេតមើលទឹកមុខ និង កាយវិការរបស់កុមារដែលនាំអោយគ្រូបង្រៀនដឹងថា កុមារចាប់អារម្មណ៍លើមេរៀន ឬ កុមារមិនយល់មេរៀន ។

ម៉្យាងទៀត គ្រូបង្រៀនត្រូវនិយាយច្បាស់លាស់ និង ដោយទឹកចិត្តពុះពារ ។ ការដែលគ្រូបង្រៀននិយាយរបៀបនេះ នាំអោយកុមារមានបំណងចង់ស្តាប់ ។ គ្រូបង្រៀនដែលនិយាយ ដោយសំលេងស្មើ គ្មានលើកដាក់ គឺថាដូចអានអក្សរ នាំឱ្យកុមារងងុយគេង ។ កុមារចូលចិត្តមើលគំនូរជីវចរ ព្រោះមានសកម្មភាព មានពណ៌ច្រើន និង មានចលនា ។ ដូចគ្នានេះដែរ បើគ្រូបង្រៀននិយាយដោយទឹកចិត្តពុះពារ ហើយធ្វើកាយវិការ និង ផ្លាស់ប្តូរទឹកមុខនោះកុមារនឹងចាប់អារម្មណ៍លើការបង្រៀន ។

កុមារអាចផ្តង់អារម្មណ៍លើសកម្មភាពមួយ តែក្នុងរយៈពេលប៉ុន្មាននាទី ដែលត្រូវសំរាប់អាយុរបស់គេប៉ុណ្ណោះ ។ ឧទាហរណ៍ កុមារអាយុប្រាំពីរឆ្នាំ អាចផ្តង់អារម្មណ៍បានល្អតែប្រាំពីរនាទីប៉ុណ្ណោះ បន្ទាប់ពីនេះ កុមារត្រូវប្តូរធ្វើអ្វីផ្សេងហើយ ។

គ្រូបង្រៀនដែលបង្រៀនបានល្អ និង ចេះបង្ហាញសេចក្តីស្រឡាញ់ដល់សិស្សរបស់ខ្លួន នោះលើកទឹកចិត្តកុមារឱ្យចូលរួមអស់ពីចិត្ត ។



គ្រូបង្រៀនដែលវៃឆ្លាត មិនបង្រៀនសេចក្តីដែលកុមារអាចរកឃើញដោយខ្លួនឯងទេ ។ ឧទាហរណ៍ : យើងមិនបង្រៀនខ្លឹមសាររបស់រ៉ូម ជំពូក ៨ ដោយអធិប្បាយពន្យល់អោយកុមារចាំតែស្តាប់ទេ ។ បើយើងនិយាយថា÷ «ឥឡូវយើងនាំគ្នារកមើលកិច្ចការអោយបានបីយ៉ាង ដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើសំរាប់យើង ដោយអានជំពូក ៨ របស់សៀវភៅរ៉ូម » នោះជាការល្អជាង ។

ចេះស្រឡាញ់មនុស្សឯទៀតប៉ុណ្ណោះទេ គឺថែមទាំងត្រូវសួរសំនួរទៅកុមារថា÷ *«តើអ្នកអាចស្រឡាញ់មនុស្សឯទៀត ដោយរបៀបណា ? »* ។ ត្រូវសរសេរចំលើយរបស់កុមារលើក្តារខៀន ។ ពួកគេប្រហែលជាឆ្លើយថា÷ *«ទៅសួរសុខទុក្ខមិត្តរួមថ្នាក់ នៅសាលារៀន ដែលឈឺ ឬ បង្រៀនមិត្តភក្តិអោយចេះអានអក្សរ ឬ ជួយមាតាបិតាយើងមើលថែទាំសត្វពាហនៈ និង ស្រែចំការ »* ។

កុមារអាយុប៉ុននេះនឹងរៀនស្រួលជាង បើសិនជាអោយកុមារា និង កុមារីនៅក្រុមផ្សេងពីគ្នា ។

កុមារអាយុប៉ុននេះ ចេះសំដែងល្ខោនដែលទាក់ទងនឹងព្រះគម្ពីរ ។

ត្រូវបង្ហាត់បង្រៀនកុមារធំៗទាំងនេះ អោយចេះបង្រៀន និង ជួយកុមារតូចៗជាង ។ កុមារធំៗទាំងនេះអាចគូររូបភាពដែលទាក់ទងនឹងរឿងនិទានរបស់ព្រះគម្ពីរ ដែលគ្រូត្រូវយកទៅបង្រៀនកុមារតូចៗនៅពេលខាងមុខ ។ ពួកគេអាចធ្វើតុក្កតា និង លេងល្ខោនតុក្កតាអោយកុមារតូចៗមើល ។ ពួកគេអាចរៀបចំ និង ហាត់និទានរឿងរបស់ព្រះគម្ពីរ ដើម្បីនិទានរឿងទាំងនោះប្រាប់កុមារតូចៗ ។

កុមារអាយុពី ១០ ឆ្នាំ ដល់វ័យជំទង់ :

បើសិនជាឱ្យកុមារអាយុប៉ុននេះ ធ្វើសកម្មភាពដូចកុមារតូចៗ នោះ កុមារទាំងនេះនឹងមិនចង់ធ្វើទេ ។ គ្រូបង្រៀនត្រូវចេះវិធីបង្រៀន ដែលត្រូវនឹងអាយុរបស់ក្រុមកុមារទាំងនេះ ។

វិធីបង្រៀនកុមារអាយុពី ១០ ឆ្នាំ ទៅវ័យជំទង់ :

- បង្រៀនមេរៀនក្នុងរយៈពេល ៣០ នាទី ដែលកុមារទាំងនេះ អាចយកទៅអនុវត្តក្នុងជីវិតគេបាន ។
- អោយកុមារសំដែងល្ខោន ដែលទាក់ទងនឹងព្រះគម្ពីរ ។
- បង្ហាត់បង្រៀនកុមារទាំងនេះ ឱ្យចេះបង្រៀនកុមារឯទៀត ។
- ណែនាំកុមារអោយចេះពិភាក្សា និង ធ្វើលំហាត់ ។

ការដែលសំខាន់ គឺមិនគ្រាន់តែបង្រៀនកុមារអាយុប៉ុននេះ អំពីខ្លឹមសាររបស់ព្រះគម្ពីរប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវបង្រៀនពួកគេឱ្យដឹងថា ខ្លឹមសាររបស់ព្រះគម្ពីរទាក់ទងនឹងជីវិតរបស់ពួកគេផងដែរ ។ លើសពីនេះទៅទៀត បង្រៀនពួកគេឱ្យចេះរបៀបយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅអនុវត្ត ។ មិនត្រឹមតែបង្រៀនកុមារអោយ

ដូចគ្នានេះដែរ បើយើងនិយាយថា÷ «ឥឡូវ យើងនាំគ្នារកមើលហេតុការណ៍ ដែលនាំឱ្យមានការបង្កើតក្រុមជំនុំនៅទីក្រុងសេសារ ដោយស្តាប់សុផាតអានអំពីលោកពេត្រុស និង លោកគ័រនេល្យូស នៅក្នុង កិច្ចការ ជំពូក ១០ » នោះជាការប្រសើរជាង ។

ត្រូវបង្រៀនយ៉ាងខ្លី ។ សំរាប់កុមារតូចៗ ត្រូវប្រើពេលតែបី ឬ ប្លននាទី សំរាប់និយាយរឿងខ្លីមួយ ហើយធ្វើអោយមេរៀនទាក់ទងនឹងជីវិតរបស់កុមារ ។ បន្ទាប់មក ត្រូវអោយកុមារធ្វើសកម្មភាពមួយ ដូចជា :

- ទន្ទេញខព្រះគម្ពីរ ។
- ផាត់ពណ៌រូបគំនូរ ។
- ច្រៀងចំរៀង ។
- ធ្វើអ្វីមួយ ដែលទាក់ទងនឹងមេរៀន ។
- សំដែងឆាកល្ខោនខ្លីៗ ។ល។ ។

© Project WorldReach © SEAN

គោលការណ៍ ទី ៤

ប្រៀនប្រដៅកុមារ



កុមារដែលមានចរិយាមិនល្អ រំខានដល់ការរៀនសូត្ររបស់កុមារឯទៀត ។ គ្រូបង្រៀនមិនត្រូវបណ្តោយអោយបាត់បង់សណ្តាប់ធ្នាប់ទេ ។ ត្រូវសុំឱ្យកុមារ ដែលមានការទទួលខុសត្រូវជាងគេជួយរក្សាសណ្តាប់ធ្នាប់ ។ ត្រូវកែតម្រង់ដោយសេចក្តីស្រឡាញ់ដោយចិត្តនឹងន ដោយត្រឹមត្រូវ និង ដោយម៉ឺងម៉ាត់ តាំងពីដំបូងទៅ ។ បើសិនជាគ្រូបង្រៀនបណ្តោយអោយមានទំលាប់អាក្រក់ កុមារនឹងមិនគោរពគ្រូបង្រៀនរបស់ខ្លួនឡើយ ។

សូមគូសពីក្រោមវិធី ដែលមានប្រសិទ្ធិភាពសំរាប់បង្រៀនកុមារដែលអាយុពី ៦ ទៅ ៩ ឆ្នាំ :

ក- អោយកុមារធ្វើសកម្មភាព ។

ខ- អោយកុមារសំដែងរឿងនិទានរបស់ព្រះគម្ពីរ ឬ ធ្វើកាយវិការដែលត្រូវនឹងរឿងនិទាន ។

គ- និយាយអោយកុមារស្តាប់ក្នុងរយៈពេលមួយម៉ោង ។

ឃ- សួរសំនួរ ។

ង- ដាក់កិច្ចការស្រួលៗអោយកុមារធ្វើ ។

ច- ចាត់តាំងកុមារអោយជួយបង្រៀនកុមារតូចៗជាង ។

ចំលើយត្រឹមត្រូវ គឺ : ក ខ ឃ ង ច ។ មិនត្រូវឱ្យកុមារនៅអង្គុយស្ងៀម ចាំតែស្តាប់អ្នកបង្រៀនទេ ។ តែត្រូវអនុញ្ញាតិអោយកុមារឆ្លើយសំនួរ សំដែងរឿងនិទានដែលបានរៀន និង ជួយធ្វើកិច្ចការខ្លះ ។

ត្រូវដាក់ភារៈកិច្ចឱ្យកុមារអាយុប៉ុននេះធ្វើ ។ កុមារទាំងនេះ អាចគួរគំនូរសំរាប់អោយកុមារតូចៗជាងផាត់ពណ៌ នៅក្នុងថ្នាក់រៀន ។ កុមារទាំងនេះ អាចនិទានរឿងអំពីទូកធំរបស់លោកណូអេ និង សំដែងឆាកកំប្លែងខ្លីៗអោយកុមារតូចៗជាងខ្លួនមើល ។ កុមារទាំងនេះ អាចជួយរៀបចំសំភារៈសំរាប់ពេលរៀន ឬ ជួយសំអាតបន្ទប់រៀន ក្រោយពេលរៀន ។

សួរសំនួរស្រួលៗ ដែលពួកគេអាចឆ្លើយបាន ។ មុននឹងនិទានរឿង អ្នកត្រូវប្រាប់អោយកុមារដឹងថា អ្នកនឹងសួរសំនួរមួយទៅកុមារ ពេលអ្នកនិទានរឿងចប់ ។ ឧទាហរណ៍ : មុននឹងនិទានរឿងនាងរ៉ូថ អ្នកត្រូវនិយាយថា÷ *«ត្រូនឹងនិយាយប្រាប់កូនទាំងអស់គ្នាអំពីមនុស្សម្នាក់ដែលបានជួយនាងរ៉ូថ អោយរួចផុតពីភាពក្រលំបាក ។ កូនៗត្រូវខំប្រឹងស្តាប់ ព្រោះពេលត្រូនិយាយរឿងចប់ ត្រូនឹងសួរកូនៗថា អ្នកណាដែលបានជួយនាងរ៉ូថ »* ។

មាតាបិតា និង គ្រូបង្រៀនត្រូវនាំកុមារអាយុប៉ុននេះ ឱ្យថ្វាយជីវិតទៅព្រះយេស៊ូ និង បង្រៀនពួកគេឱ្យចេះអធិស្ឋាន អានព្រះគម្ពីររបស់គេ ទៅព្រះវិហារទៀងទាត់ ដាក់ដង្វាយ និង និទានរឿងអំពីព្រះយេស៊ូប្រាប់មនុស្សឯទៀត ។

របៀបកែតម្រង់កុមារ ដែលគ្មានសណ្តាប់ធ្នាប់ :

- ឈប់និយាយ ហើយសម្លឹងមើលមុខកុមារ ដោយស្ងៀមស្ងាត់ រហូតទាល់តែគេនៅស្ងៀម ។
- កុំស្រែកដាក់កុមារឱ្យសោះ គឺត្រូវសួរកុមារ ដែលគ្មានរបៀបនោះ ដោយសំលេងធម្មតាថា÷ «កូនកំពុងធ្វើអ្វីហ្នឹង?» និង ថា÷ «កូនដឹងថាអាកប្បកិរិយារបស់កូនរំខាន ដល់សិស្សឯទៀតដែរទេ ? » និង ថា÷ «តើព្រះជាម្ចាស់ពេញចិត្តនឹងអាកប្បកិរិយារបស់កូនឬទេ ? ព្រោះអ្វី?» ។ សូមទុកអោយកុមារឆ្លើយ ហើយទុកឱកាសអោយកុមារនោះដឹងពីកំហុសរបស់ខ្លួន និង ទទួលសារភាពកំហុសរបស់ខ្លួន ។
- សុំអោយឪពុកម្តាយរបស់កុមារ ដែលមិនចេះស្តាប់ ជួយណែនាំកូនៗរបស់ខ្លួន អោយកែប្រែអាកប្បកិរិយា ។
- ដាក់កុមារអោយអង្គុយក្បែរគ្រូបង្រៀន ។
- បើកុមាររពឹសពេក ត្រូវអោយកុមារធ្វើអ្វីមួយ ដែលមានប្រយោជន៍ ដូចជាសុំអោយគេជួយអ្នកធ្វើអ្វីមួយ ឬ ជួយកុមារផ្សេងទៀត ។

© Project WorldReach © SEAN

- និយាយជាមួយកុមារនោះ ដោយផ្ទាល់ ហើយអោយកុមារនោះជួយអ្នកនៅក្នុងថ្នាក់ ដើម្បីអោយគេជឿជាក់ថា អ្នករាប់អានគេមែន ។

រៀបចំកន្លែងមួយដែលសមរម្យ គួរទាក់ទាញចិត្តកុមារ បើអាចធ្វើបាន ។ បើសិនជាបន្ទប់ក្តៅពេក ឬ ត្រជាក់ពេក ឬ ខ្វះកន្លែងអង្គុយ កុមារមិនអាចផ្តង់អារម្មណ៍បានល្អទេ ។



គ្រូអាចនិទានរឿងក្នុងរយៈពេល ពី ១៥ ទៅ ២0 នាទី បើសិនជាកុមារចូលរួមដោយធ្វើកាយវិការ ឬ សំដែងរឿងខ្លីៗ ដូចជាឆាកកំប្លែងអំពីទូកធំរបស់លោកណូអេ ។

កុមារអាយុប៉ុននេះ អាចធ្វើកិច្ចការបានច្រើនលើសពីការផ្ចាត់ពណ៌ ។ ពួកគេអាចគូររូបភាពដែលទាក់ទងនឹងរឿងនិទាន រួចផ្ចាត់ពណ៌ ហើយកាត់ចេញ ។

ពេលអ្នកបង្រៀន អ្នកត្រូវប្រើឧទាហរណ៍បំភ្លឺ ។ ឧទាហរណ៍ : បើអ្នកបង្រៀនពីវគ្គព្រះគម្ពីរ ម៉ាកុស ៧:១៤-២៣ សូមយកកែវមួយដែលស្អាតតែខាងក្រៅ តែក្រខ្វក់ខាងក្នុង និង កែវមួយទៀតដែលស្អាតទាំងខាងក្រៅ ទាំងខាងក្នុងមកបង្ហាញកុមារ ។ រួចសួរកុមារថា÷ *«តើកូនយកកែវណាមួយទៅដងទឹកញ៉ាំ ? ព្រោះអ្វី ? »* ។ បន្ទាប់មក ពន្យល់កុមារថា÷ *«យើងទាំងអស់គ្នាសុទ្ធតែចង់យកកែវដែលស្អាតទាំងខាងក្នុង ទាំងខាងក្រៅទៅដងទឹកញ៉ាំ ។ ព្រះ-យេស៊ូក៏មានព្រះហឫទ័យដូច្នេះដែរ ព្រះអង្គចង់សំអាតយើងអោយជ្រះស្អាតពីអំពើបាបដែលនៅក្នុងយើង »* ។ ត្រូវប្រើរបស់សាមញ្ញដែលកុមារស្គាល់ច្បាស់ និង ធ្លាប់ឃើញ និង ធ្លាប់ប្រើរាល់ថ្ងៃ ដើម្បីបង្រៀន ។

ក្រោយដែលបាននិទានរឿងមួយរបស់ព្រះគម្ពីរចប់ហើយ គ្រូអាចឱ្យកុមារសំដែងរឿងនោះ ។ ឧទាហរណ៍ : ក្រោយដែលអ្នកនិទានរឿងអំពីលោកណូអេ និង ទឹកធំហើយ គ្រូត្រូវអោយកុមារសំដែងធ្វើជាសត្វ ដែលនាំគ្នាចូលទៅក្នុងទូកធំមួយគូៗ ។

ត្រូវនិយាយថា÷ «ឥឡូវនេះ យើងនឹងធ្វើដូចសត្វដែលនាំគ្នាចូលទៅក្នុងទូកធំ ។ រតនា និង សោភ័ណត្រូវធ្វើជាដំរី អ្នកត្រូវយកដៃរបស់អ្នកធ្វើជាប្រមោយ ។ ពៅ និង ម៉ៅធ្វើជាក្របី ដោយដើរបោះជំហានយឺតៗ អ៊ីកអៀកៗ ។ ធីតា និង កូឡាបធ្វើជាស្វា ដោយលើកដៃឡើងលើគ្រវីទៅមកយ៉ាងខ្ពស់ ។ ធឿនធ្វើជាណូអេ ដែលនាំសត្វចូលទៅក្នុងទូក ។ ឥឡូវ ត្រូវនាំគ្នាមកត្រង់នេះទាំងអស់គ្នា ព្រោះទូកនៅជ្រុងម្ខាងទៀតនៃបន្ទប់ ។ ទាំងអស់គ្នាប្រុងប្រៀបហើយឬនៅ ? ។ ភ្លៀងចាប់ផ្តើមធ្លាក់ហើយ ផ្គឹកផ្គុក ! ផ្គឹកផ្គុក ! ។ ទឹកចាប់ផ្តើមឡើងហើយ ! លោកណូអេចាប់ផ្តើមនាំសត្វដើរចូលក្នុងទូកមួយគូម្តងៗ ។ គាត់បើកទ្វារទូក ហើយដំរីចូលក្នុងទូកមុនគេ ។ ឥឡូវដល់វេនក្របី រួចស្វា ។ លោកណូអេបិទទ្វារទូក ! » ។

គោលការណ៍ ទី ៥

បង្រៀនកុមារអោយចេះអនុវត្តតាមព្រះបន្ទូល



កុមារត្រូវធ្វើកិច្ចការ ស្របទៅតាមមេរៀនដែលគេបានសិក្សា ។

បើសិនជាកុមារគ្រាន់តែស្តាប់គ្រូបង្រៀន នោះគ្មានប្រយោជន៍ទេ ។ ព្រោះអ្វី ? (យ៉ាកុប ១:២២) ។

គ្រូបង្រៀន និង កុមារត្រូវរៀបចំអោយមានការអនុវត្តតាមមេរៀន គឺកុមារត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ :

- កុមារទទួលព្រះគ្រីស្តជាព្រះសង្គ្រោះ និង ជាព្រះអម្ចាស់ ។
- កុមារទទួលពិធីជ្រមុជទឹក និង ចូលរួមធ្វើពិធីកាច់នំប៉័ង ។
- កុមារជួយក្រុមជំនុំ ដោយដាក់ដង្វាយ និង ជួយធ្វើកិច្ចការផ្សេងៗ ។
- កុមារផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត និង ចូលរួមធ្វើសកម្ម-ភាពរបស់ក្រុមជំនុំ ។
- កុមារបង្ហាញសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តនៅផ្ទះ នៅសាលា និង នៅគ្រប់ទីកន្លែង ។
- កុមារជួយមនុស្សឈឺ និង មនុស្សដែលខ្វះខាត ។

កុមារអាយុពី ៦ ឆ្នាំ ទៅ ៩ ឆ្នាំ :

កុមារអាយុប៉ុននេះ ចូលចិត្តចូលរួម និង ធ្វើសកម្មភាពជាងអង្គុយស្តាប់គ្រូបង្រៀន ។ ដូច្នេះ គ្រូត្រូវចេះបង្កើតឱកាស ដែលនាំឱ្យកុមារអាចចូលរួមក្នុងមេរៀនបាន ។

វិធីសំរាប់បង្រៀនកុមារដែលអាយុពី ៦ ឆ្នាំ ទៅ ៩ ឆ្នាំ :

- និទានរឿងក្នុងរយៈពេល ១៥-២០ នាទី ដោយអោយកុមារធ្វើកាយវិការ ឬ សំដែងរឿងដែលអ្នកបាននិទាន ។
- ធ្វើសកម្មភាពដែលកុមារទាំងអស់អាចធ្វើជាមួយគ្នា ។
- ពេលអ្នកបង្រៀន អ្នកត្រូវប្រើឧទាហរណ៍ ការប្រៀបធៀប និង ឧទាហរណ៍បំភ្លឺ ។
- ដាក់ភារៈកិច្ចអោយកុមារធ្វើ ។
- សួរសំនួរស្រួលៗ ។
- អោយកុមាររៀបចំរបៀប ដែលគេអាចយកសេចក្តីដែលគេបានរៀនទៅអនុវត្ត ។
- ណែនាំឪពុកម្តាយ និង គ្រូបង្រៀនឱ្យនាំកុមារ អោយថ្វាយខ្លួនទៅព្រះគ្រីស្ត ។
- បង្រៀនកុមារអោយចេះប្រតិបត្តិតាមព្រះគ្រីស្ត ។

កុមារអោយធ្វើតាមអ្នក ឬក៏អោយកុមារសំដែងរឿង ដោយធ្វើកាយវិការ និង បញ្ចេញសូរសម្លេង ។

បើសិនជាអ្នកនិយាយពីទារកម៉ូសេ នៅក្នុងកញ្ជ្រែងអណ្តែតលើទឹកទន្លេនីល អ្នកត្រូវយោលដៃទាំងពីរទៅមក ដូចជាកញ្ជ្រែង ហើយនិយាយថា÷ *«ទារកម៉ូសេ អណ្តែតទៅ អណ្តែតទៅ អណ្តែតទៅតាមខ្សែទឹកហូរ »* ។

ក្រោយពេលនិយាយរឿងមួយហើយ ត្រូវសួរសំនួរស្រួលៗ ។ ឧ. បើអ្នកនិទានរឿងអំពីដាវីឌ និង កូលីយ៉ាត សូមសួរសំនួរដូចនេះ : *«តើអ្នកណាសំឡាប់មនុស្សមាឌធំ ដែលចិត្តអាក្រក់នោះ ? »* ឬ *«តើដាវីឌប្រើអ្វី ដើម្បីសំឡាប់មនុស្សមាឌធំដូចយក្សនោះ ? »* ។

សូមគូសពីក្រោមវិធី សំរាប់បង្រៀនកុមារដែលអាយុពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ :

ក- និទានរឿងម្តងហើយ ម្តងទៀតច្រើនដង ។

ខ- និទានរឿង ដោយធ្វើកាយវិការ ។

គ- សួរសំនួរស្រួលៗ ។

វិធីទាំងអស់នេះ មានប្រសិទ្ធិភាពណាស់ សំរាប់បង្រៀនកុមារ ។

គោលដៅរបស់គ្រូបង្រៀនព្រះគម្ពីរ គឺអោយកុមារម្នាក់ៗចេះធ្វើការងារថ្វាយព្រះជាម្ចាស់ ទោះតិចតួចក៏ដោយ ។ ឧទាហរណ៍ : កុមារធំៗអាចធ្វើជាអ្នកជំនួយ ជួយកុមារតូចៗអោយចេះនូវអ្វីដែលខ្លួនបានដឹងរួចហើយ ។ កុមារឯទៀតអាចផ្សាយដំណឹងល្អ ប្រាប់មិត្តភក្តិ ឬ ធ្វើកិច្ចការល្អមួយចំពោះអ្នកជិតខាង ។ល។ ។

គ្មានអ្នកណាអាចចេះធ្វើកិច្ចការមួយអោយបានល្អ ដោយគ្រាន់តែឮគេនិយាយពីសកម្មភាពនោះទេ ។ អ្នកលេងបាល់ទាត់ មិនមែនចេះលេង ដោយគ្រាន់តែអានសៀវភៅទេ ។

យើងបង្រៀន ដោយពន្យល់ព្រះគម្ពីរ និង ដោយធ្វើជាគំរូតាមព្រះបន្ទូលដែរ ។ នៅក្នុងមេរៀននិមួយៗ យើងត្រូវដាក់កិច្ចការខ្លះ ដែលត្រូវនឹងមេរៀននោះ អោយកុមារធ្វើ ។ យ៉ាកុប ១:២២ បង្គាប់យើងថា÷

«ចូរប្រតិបត្តិតាមព្រះបន្ទូល កុំគ្រាន់តែស្តាប់ទាំងបញ្ឆោតចិត្តខ្លួនឯងប៉ុណ្ណោះឡើយ » ។

ហេតុអ្វីបានជាត្រូវបញ្ចូលកិច្ចការអនុវត្ត ទៅក្នុងមេរៀននិមួយៗ ? ។

© Project WorldReach © SEAN

មេរៀននិមួយៗត្រូវមានផ្នែកអនុវត្តការងារ ដើម្បីអោយកុមារធ្វើអ្វីមួយ ស្របតាមមេរៀន ។ កុមារមិនមែនគ្រាន់តែជាអ្នកស្តាប់ព្រះបន្ទូលប៉ុណ្ណោះទេ ។ បើគ្រីស្តជនមិនបំរើព្រះជាម្ចាស់ទេ នោះគេជាមនុស្សដែលបញ្ឆោតខ្លួនឯង ។

ការរៀបចំ ការបង្រៀន ការអនុវត្តតាម



បើកង់ណាមួយនៃច្រវ៉ាក់នេះបាក់ ក៏លែងមានប្រយោជន៍ដែរ ។ តើមេរៀននឹងមានប្រយោជន៍អ្វី បើសិនជាគ្រូបង្រៀនមិនបានរៀបចំមេរៀននោះអោយបានល្អ ? ។

ជាមួយកុមារអាយុប៉ុននេះ អ្នកអាចនិទានរឿង ក្នុងរយៈពេលយូរបន្តិច ។ សូមកុំភ្លេចធ្វើចលនា ផ្លាស់ប្តូរទឹកមុខ និង លើកដាក់សម្លេងផង ពេលនិទានរឿង ដើម្បីធ្វើឱ្យក្មេងសប្បាយចិត្តនឹងស្តាប់ ។

នេះជាយោបល់ខ្លះ :

មុននឹងបង្រៀនសិស្ស ត្រូវរៀបចំរូបភាពសំរាប់អោយកុមារផាត់ពណ៌ គឺត្រូវរៀបចំរូបភាពអំពីមនុស្ស ឬ របស់ដែលមាននិយាយនៅក្នុងរឿងនិទាន ដែលអ្នកនឹងនិទាន ។ នៅពេលដែលកុមារផាត់ពណ៌រូបភាពរួចហើយ ទើបអ្នកនិទានរឿងប្រាប់ ។ នៅពេលដែលអ្នកនិយាយពីមនុស្សម្នាក់ ឬ របស់ដែលកុមារបានផាត់ពណ៌ ត្រូវអោយកុមារលើករូបភាពរបស់ពួកគេឡើង ។ ឧ. កុមារផាត់ពណ៌លើរូបគំនូរអំពីស្តេចដាវីឌ ។ នៅពេលដែលអ្នកនិទានរឿងអ្នកត្រូវអោយកុមារលើករូបរបស់ស្តេចដាវីឌ នៅរាល់ពេលដែលអ្នកនិយាយឈ្មោះដាវីឌ ។ សកម្មភាពនេះ ជួយកុមារអោយអាចផ្ចង់ស្មារតីស្តាប់ ។

បើសិនជាអ្នកនិយាយអំពីពួកសាវ័កជិះទូកក្នុងសមុទ្រ ពេលមានខ្យល់ព្យុះ សូមធ្វើចលនាតាមទូក ដែលយោលចុះ យោលឡើង ដោយសារទឹករលក ។ សូមធ្វើចលនានេះច្រើនដង រួចប្រាប់

© Project WorldReach © SEAN

ចំលើយត្រឹមត្រូវ គឺ : ខ គ ង ច និង ឆ ។ កុមារអាយុប៉ុន នេះ មិនអាចប្រុងស្តាប់រឿងវែងៗបានទេ ។ កុមារតូចៗមិនយល់ ពីគោលជំនឿទេ ។ មិនចាំបាច់ទិញកូនរូប និង រូបភាពថ្លៃៗទេ គឺកុមារតូចៗចូលចិត្តរបស់សាមញ្ញ ដែលធ្វើដោយដៃវិញ ។

កុមារអាយុពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ :

កុមារដែលមានអាយុប៉ុននេះ ចូលចិត្តសកម្មភាពដូចកុមារដែលអាយុពី ១ ឆ្នាំកន្លះទៅ ៣ ឆ្នាំដែរ ។ ប៉ុន្តែ កុមារប៉ុននេះ អាចចូលរួមរៀនច្រើនជាង និង ប្រុងស្តាប់បានយូរជាង ។

វិធីសំរាប់បង្រៀនកុមារដែលអាយុពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ :

- និទានរឿង ដោយធ្វើកាយវិការ ផ្លាស់ប្តូរទឹកមុខ និង លើកដាក់សម្លេងក្នុងរយៈពេល ៥-១០ នាទី ។
- នៅពេលដែលអ្នកនិទានរឿង សូមអោយកុមារធ្វើកាយវិការស្របទៅតាមសាច់រឿង ។
- បង្រៀនកុមារអោយចេះសំដែងសាច់រឿង (ជាពិសេសធ្វើកាយវិការ និង សូរសម្លេង) ។
- អោយកុមារនិយាយតាមអ្នក និង ធ្វើកាយវិការតាមអ្នក ។
- សួរសំណួរស្រួលៗ ។

បើសិនជាគ្រូបង្រៀនរៀបចំបានល្អ និង ធ្វើអោយសិស្សមានការងារអនុវត្តធ្វើ នោះមេរៀនរបស់គាត់នឹងកសាងកុមារឡើងមិនខាន ។ បើសិនជាកុមារមិនធ្វើការងារអនុវត្ត ហេតុអ្វីបានជាគេមិនរីកចំរើនឡើង ? ។

_____

_____

_____

_____

ការយកព្រះបន្ទូលមកអនុវត្តក្នុងជីវិតរបស់សិស្ស ជាគោលដៅរបស់មេរៀនគ្រប់យ៉ាង សំរាប់បង្រៀនគ្រីស្តជន ។

តើចំណុចចាំបាច់ទាំងបីរបស់មេរៀននិមួយៗ គឺអ្វីខ្លះ ?

១- ការរៀប _____

២- ការប _____

៣- ការអ _____

មេរៀននិមួយៗត្រូវការអោយមាន «ការរៀបចំ» «ការបង្រៀន» និង «ការអនុវត្ត» ។

ការរៀបចំ រួមមានការអធិស្ឋាន ការស្វែងយល់ពីសេចក្តីត្រូវការរបស់កុមារ ការសិក្សាអត្ថបទព្រះគម្ពីរ ការសរសេរមេរៀន និង ការរៀបចំកម្មវិធីបង្រៀន ដូចជាការបែងចែកផ្នែកខ្លះឱ្យគ្រូជំនួយធ្វើ ការរៀបចំសម្ភារៈ និង ការរៀបចំសកម្មភាពផ្សេងៗ ។ល។ ។

ការបង្រៀន រួមមានការបង្រៀនមេរៀនដែលបានរៀបចំ និង សួរសំនួរ ដើម្បីបញ្ជាក់ថា កុមារទាំងអស់ពិតជាបានយល់ និង អនុវត្តតាមសេចក្តី ដែលបានរៀនក្នុងជីវិតរបស់ខ្លួន ។ បើសិនជាកុមារម្នាក់មិនអាចឆ្លើយសំនួរមួយបាន ត្រូវធ្វើសំនួរស្រួលៗសំរាប់សួរវិញ ។

ការអនុវត្ត រួមមានកិច្ចការដែលកុមារត្រូវធ្វើ ដើម្បីប្រតិបត្តិតាមសេចក្តីបង្រៀន ។ ជំបូង ក្នុងមេរៀន គ្រូបង្រៀនត្រូវពន្យល់ឱ្យច្បាស់ពីកិច្ចការដែលកុមារត្រូវធ្វើសិន ។ មិនត្រូវបង្រៀនគោលជំនឿព្រះគម្ពីរ ដោយគ្មានយកមកអនុវត្តភ្លាមៗទេ ។ ជួនកាលត្រូវដាក់កិច្ចការអោយកុមារធ្វើនៅផ្ទះ ជាការអនុវត្ត ។ ជួនកាលទៀត កុមារត្រូវនិយាយរឿងព្រះគម្ពីរ និង ពន្យល់ពីរបៀបដែល

សូមគូសពីក្រោមតែវិធីប្រាំ ដែលសំរាប់បង្រៀនកុមារតូចៗ :

ក- អានរឿងវែងៗ ។

ខ- និទានរឿងខ្លីៗ ។

គ- បង្រៀនចំណុចសំខាន់ៗឡើងវិញច្រើនដង និង អោយកុមារច្រៀងចំរៀង ដែលមានខ្លឹមសារឡើងវិញច្រើនដង ។

ឃ- ទិញរូបភាពថ្លៃៗ សំរាប់ធ្វើជាឧទាហរណ៍បំភ្លឺ ។

ង- អោយកុមារផាត់ពណ៌រូបភាព ដែលគេគួរធម្មតា មិនមែនទិញគេ ។

ច- ធ្វើសួរសម្តែងនៅពេលនិទានរឿង ហើយអោយកុមារធ្វើតាមសួរសម្តែងទាំងនោះ ។

ឆ- ប្រើកូនរូប និង ធ្វើអោយកូនរូបនោះធ្វើចលនា ដែលត្រូវនឹងរឿងនិទាន ។

ជ- សួរសំនួរពីគោលជំនឿ ។

លើសពីនេះទៅទៀត កុមារចូលចិត្តស្តាប់សួរសម្តែង និង ធ្វើតាម ។ ឧទាហរណ៍ : សូមកុំគ្រាន់តែនិយាយថា÷ *«នាងម៉ារីជិះលើខ្នងលា ធ្វើដំណើរទៅភូមិបេថ្លេហិម »* តែសូមនិយាយថា÷ *«នាងម៉ារីជិះលើខ្នងលា ធ្វើដំណើរទៅភូមិបេថ្លេហិម ហើយលាដើរក្តីប ក្តុប ក្តីប ក្តុប »* ។ ពេលដែលនិយាយឃ្លានេះចប់ហើយ សូមបង្រៀនកុមារពីរបៀបធ្វើសម្តែងលាដើរ ។ បន្ទាប់មក និយាយឃ្លានេះម្តងទៀត ហើយអោយកុមារធ្វើតាមសម្តែងលាដើរជាមួយអ្នក ។

ត្រូវដឹកនាំកុមារឱ្យច្រៀងចំរៀងខ្លីៗ ដែលកុមារស្រួលចាំ ។ បើច្រៀងចំរៀងតិច តែច្រើនដង នោះមានប្រយោជន៍ជាងច្រៀងចំរៀងច្រើន តែមិនច្រៀងឡើងវិញច្រើនដង ។ ការធ្វើឡើងវិញដដែលៗ ជួយឱ្យកុមារអាយុប៉ុននេះចាំ និង ចេះអ្វីៗដែលគេកំពុងរៀន ។ ពេលច្រៀង អោយកុមារធ្វើកាយវិការដែរ ។ កាយវិការនេះ ត្រូវតែជាកាយវិការ ដែលស្រួលធ្វើ ដូចជា : ងើបឈរ ដើរ លោត ដើរជុំវិញ...។ល។ ។

ត្រូវប្រតិបត្តិតាមរឿងព្រះគម្ពីរនោះ ប្រាប់ឪពុកម្តាយ មិត្តភក្តិ ឬ កុមារតួចជាងដែលរៀនជាមួយខ្លួន ។ ត្រូវទុកពេលសំរាប់អោយគ្រូជំនួយនិយាយជាមួយកុមារម្នាក់ៗ ពីរបៀបដែលកុមារអាចយកមេរៀនទៅអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។

តើរបៀបណាដែលប្រសើរជាងគេ សំរាប់អនុវត្តមេរៀនអំពីការស្រឡាញ់អ្នកជិតខាងរបស់ខ្លួន ?

- ☐ អានរឿងអំពីអ្នកស្រុកសាម៉ារីម្នាក់ដែលមានចិត្តសប្បុរស ។
- ☐ ទៅសួរសុខទុក្ខមិត្តភក្តិដែលឈឺ និង យកអំណោយខ្លះទៅជូន ឬក៏និទានរឿងមួយប្រាប់អ្នកនោះ ។
- ☐ ទន្ទេញខគម្ពីរមួយអំពីសេចក្តីស្រឡាញ់អោយចាំស្ទាត់ ។

ការអនុវត្តដែលប្រសើរបំផុត គឺទៅសួរសុខទុក្ខអ្នកជំងឺ ព្រោះជាកិច្ចការ ដែលយើងត្រូវធ្វើចំពោះមនុស្សឯទៀត ។

មេរៀនមួយ ដែលគ្មានការអនុវត្ត ជាមេរៀនដែលមិនស្របទៅតាមគោលការណ៍របស់ព្រះគម្ពីរទេ ។ ព្រោះអ្វី ? ។

ព្រះអម្ចាស់យេស៊ូគ្រីស្ត និង អ្នកសរសេរព្រះគម្ពីរ មិនបានបង្រៀន
គោលជំនឿ ដើម្បីគ្រាន់តែឱ្យមនុស្សស្រឡាញ់គោលជំនឿប៉ុណ្ណោះ
ទេ ។ ព្រះអង្គ និង ពួកអ្នកទាំងនោះបង្រៀន ដើម្បីអោយមនុស្ស
ប្រតិបត្តិតាម ដោយកែប្រែចិត្តគំនិតរបស់ខ្លួន និង ធ្វើតាមព្រះ-
ហឫទ័យរបស់ព្រះជាម្ចាស់ ។ នេះជាមូលហេតុ ដែលនាំអោយ
គ្រូជំនួយត្រូវជួយកុមារម្នាក់ៗឱ្យអាចធ្វើការងារអនុវត្ត ។ នៅពេល
រៀនព្រះគម្ពីរក្នុងថ្នាក់ កុមារក្នុងក្រុមទាំងអស់រៀនជាមួយគ្នាមួយ
រយៈ បន្ទាប់មក គ្រូជំនួយជួបជាមួយកុមារម្នាក់ៗ ដោយផ្តាល់មួយ
រយៈដែរ ។

គ្រូជំនួយត្រូវជួយកុមារឱ្យអាចរៀបចំគំរោងផែនការ សំរាប់កិច្ចការ
ដែលត្រូវអនុវត្ត ។ ឧទាហរណ៍ : នៅពេលរៀនអំពីការផ្សាយ
ដំណឹងល្អ ពួកគេព្រមព្រៀងគ្នាឱ្យកុមារម្នាក់ៗ និយាយពីព្រះគ្រីស្ត
ប្រាប់អ្នកណាម្នាក់ នៅក្នុងអាទិត្យនោះ ។ ត្រូវអោយកុមារកត់
ឈ្មោះអ្នកនោះទុក ដើម្បីអោយកុមារចាំ ។ កុមារត្រូវខិតខំនាំអ្នក
នោះអោយបានមកចូលរួមការប្រជុំលើកក្រោយ ។ បើសិនជាត្រូវ
រៀនអំពីការថ្វាយដង្វាយ ពួកគេអាចព្រមព្រៀងគ្នាដាក់ដង្វាយទាំង
អស់គ្នា សំរាប់គំរោងពិសេសមួយ ។ គ្រូបង្រៀនសរសេរផែនការ
ទាំងនេះទុកជា «កិច្ចការដែលត្រូវអនុវត្ត » ។ នៅពេលប្រជុំលើក



ពេលនិទានរឿងគ្រូត្រូវកាន់កូនរូបធ្វើចលនា ។ ឧទាហរណ៍ កុំ
គ្រាន់តែលើកកូនរូបបង្ហាញអោយកុមារឃើញ ហើយនិយាយថា៖
«ពេលលោកអប្រាហាំដើរពីក្រុងអ៊ួរ ទៅទឹកដីសន្យា » តែត្រូវកាន់
កូនរូបធ្វើចលនា ដើរចេញទៅរកមាត់ទ្វារ ហើយនិយាយបណ្តើរ
ថា៖ *«លោកអប្រាហាំដើរចេញពីក្រុងអ៊ួរ ហើយដើរ ដើរ ដើរ
ដើរទៅរកទឹកដីសន្យា »* ។

© Project WorldReach © SEAN

ដោយសារកុមារផ្តង់អារម្មណ៍បានតែមួយរយៈពេលខ្លី សូមនិទានរឿងតែក្នុងមួយ ឬ ពីរនាទីបានហើយ ។ បើរឿងវែងពេក សូមនិទានតែផ្នែកដែលគួរចាប់អារម្មណ៍ និង ស្រួលយល់បានហើយ ។

ពេលនិទានរឿង សូមបង្ហាញរូបភាព ឬ វត្ថុផង ។ កុមារអាយុប៉ុននេះ ចូលចិត្តមើលវត្ថុ ឬ រូបភាពក្នុងរយៈពេល ១០ វិនាទី ។

គ្រូបង្រៀនមិនចាំបាច់ទិញរូបភាពថ្លៃៗ ដើម្បីធ្វើជាឧទាហរណ៍បំភ្លឺរឿងនិទានទេ ។ គ្រូបង្រៀន គ្រូជំនួយ និង កុមារធំៗអាចជួយគូររូបភាពសាមញ្ញៗ រួចផាត់ពណ៌រូបភាពទាំងនោះ និង កាត់ចេញ ។ ការដែលគ្រូជំនួយ និង កុមារធំធ្វើរូបភាព ឬ កូនរូបយកមកបង្ហាញកុមារ នាំអោយកុមារផ្សេងៗទៀតចង់ធ្វើតាមដែរ ។ ក្រៅពីគូររូបភាពលើក្រដាស និង ធ្វើកូនរូបពីក្រដាស ពួកគេអាចធ្វើរបស់ផ្សេងៗ តាមរបៀបផ្សេង ដែលអាចប្រើជាឧទាហរណ៍បំភ្លឺរឿងនិទានដែរ ។ ឧទាហរណ៍ គ្រូអាចផាត់ពណ៌ធ្វើភ្នែកពីរលើដុំក្រួសតូចមួយ ហើយយកដុំក្រួសតូចនោះទៅបង្ហាញកុមារ និង និយាយថា÷ «នេះគឺលោកពេត្រុស» ។ ម្យ៉ាងទៀត គ្រូអាចដេរក្រណាត់ធ្វើតុក្កតា ឬ ធ្វើកូនរូបពីក្រដាសកាតុងដែរ ។

ក្រោយ គ្រូបង្រៀនត្រូវតែពិនិត្យមើលថា កុមារបានបំពេញការងារអនុវត្តដែរ ឬ អត់ ។

គោលការណ៍ ទី ៦

ត្រួតពិនិត្យមើលកិច្ចការអនុវត្តរបស់កុមារ

គ្រូបង្រៀនត្រូវជួយកុមារឱ្យអាចបំពេញកិច្ចការអនុវត្តរបស់ខ្លួន ។



រាល់អាទិត្យ គ្រូបង្រៀនត្រូវសួរកុមារថា បានធ្វើកិច្ចការអនុវត្ត សំរាប់អាទិត្យមុនដែរឬទេ ។ កុមារត្រូវប្រាប់ពីកិច្ចការ ដែលខ្លួន បានធ្វើ ។ គ្រូបង្រៀន ត្រូវសរសើរកុមារដែលបានបំពេញកិច្ចការ របស់ខ្លួន ។ ធ្វើដូចនេះ លើកទឹកចិត្តកុមារអោយបន្តធ្វើដូចនេះ ទៀត និង ជំរុញកុមារឯទៀតអោយធ្វើដូចគ្នានេះដែរ ។ បើសិន ជាគ្រូជំនួយទៅសួរសុខទុក្ខកុមារនៅតាមផ្ទះ ដើម្បីជួយកុមារធ្វើ កិច្ចការរបស់ខ្លួននោះ កុមារនឹងចាប់ផ្តើមនឹកឃើញ ហើយឆាប់ បំពេញកិច្ចការរបស់ខ្លួន ។

ដាស់តឿនជំរុញគ្រូបង្រៀន និង គ្រូជំនួយអោយទុកពេលជួបជា មួយកុមារ ដែលរៀនមិនទាន់គេ ។ កុមារឯទៀត អាចធ្វើជាអ្នក ជំនួយ ដើម្បីជួយកុមារ ដែលត្រូវការជំនួយលើសពីធម្មតា ។

តើអ្នកនឹងធ្វើឱ្យកុមារអាចបំពេញការងារអនុវត្តរបស់ខ្លួន ដោយ របៀបណា ? ។

ទេ ។ ត្រូវបែងចែកកុមារជាក្រុមតាមអាយុ ហើយក្រុមកុមារ និមួយៗនោះ ត្រូវរៀនថ្នាក់ជាមួយគ្នា ។ គ្រូត្រូវចេះប្រើវិធីបង្រៀន ផ្សេងៗដែលត្រូវនឹងក្រុមកុមារផ្សេងៗ ។ ត្រូវបង្ហាញគ្រូបង្រៀនអំពី របៀបបង្រៀនកុមារ តម្រូវទៅតាមអាយុរបស់កុមារ ។

កុមារអាយុពី ១ ឆ្នាំកន្លះទៅ ៣ ឆ្នាំ :

កុមារអាយុប៉ុននេះ អាចធ្វើបានសកម្មភាពបីយ៉ាង : គឺស្តាប់រឿង និទានខ្លីៗ ច្រៀងចំរៀង និង លេងរបស់ផ្សេងៗ ។

វិធីបង្រៀនកុមារដែលមានអាយុពី ១ ឆ្នាំកន្លះ ទៅ ៣ ឆ្នាំ :

- និទានរឿងមួយក្នុងរយៈពេល ១ ទៅ ២ នាទី ។
- បង្ហាញរូបភាព ឬ របស់ដែលត្រូវនឹងរឿងនិទាននោះ (បង្ហាញរូបភាពនិមួយៗក្នុងរយៈពេល ១០-១៥ វិនាទី) ។
- ពេលនិទានរឿង គ្រូត្រូវកាន់កូនរូបធ្វើចលនា ។
- អោយកុមារចូលរួមក្នុងការនិទានរឿងដែរ ដោយធ្វើកាយ វិការ ឬ បព្ចោញសូរសម្តែង ។
- បង្រៀនឡើងវិញច្រើនដង ។

យើងប្រើចំរៀង ដែលត្រូវនឹងអាយុរបស់កុមារក្នុងក្រុមនិមួយៗ គឺ :

- ចំរៀងណាដែលមានខ្លឹមសារ អំពីអ្វីៗដែលទាក់ទងនឹងព្រះ-ជាម្ចាស់ ។
- ចំរៀងណាដែលជួយកុមារឱ្យអាចថ្វាយបង្គំព្រះជាម្ចាស់ ។
- ក្នុងពេលប្រជុំមួយ មិនត្រូវច្រៀងចំរៀងទាំងអស់តែម្តងទេ គឺច្រៀងពេលផ្សេងៗគ្នា ។
- ឧស្សាហ៍ច្រៀងចំរៀង ដែលមានខ្លឹមសារល្អៗ ដើម្បីអោយកុមារឆាប់ចេះ ។

វិធីបង្រៀនសំរាប់ក្រុមកុមារផ្សេងៗ តាមអាយុរបស់កុមារ

គ្រូបង្រៀនត្រូវរៀបចំមេរៀនតម្រូវទៅតាមអាយុរបស់កុមារ ។ គេអាចចែកកុមារជាបួនប្រភេទតាមអាយុ : កុមារអាយុពី ១ ឆ្នាំកន្លះ ទៅ ៣ ឆ្នាំ កុមារអាយុពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ កុមារអាយុពី ៦ ឆ្នាំ ទៅ ៩ ឆ្នាំ និង កុមារអាយុពី ១០ ឆ្នាំ ទៅវ័យជំទង់ ។ បើសិនជាគ្រូត្រូវបង្រៀនថ្នាក់មួយ ដែលកុមារមានអាយុផ្សេងគ្នាទាំងអស់ គ្រូមិនអាចបង្រៀនកុមារទាំងអស់ ប្រកបដោយប្រសិទ្ធិភាព

គោលការណ៍ ទី ៧

រៀបចំការសិក្សាដែលត្រូវសំរាប់កុមារ

ខាងក្រោមនេះ មានគំរូសំរាប់កម្មវិធីបង្ហាត់បង្រៀន :

- ការអធិស្ឋាន ។
- ការសរសើរតម្កើង ។
- ការអធិស្ឋានតាមសំណូមពរ ។
- ការបង្រៀនព្រះគម្ពីរយ៉ាងខ្លី ដោយនិទានរឿងព្រះគម្ពីរ និងសួរសំនួរ ។
- ការប្រាប់ដំណឹងផ្សេងៗ ។
- ការបង្ហាត់បង្រៀនកុមារម្នាក់ៗដោយផ្ទាល់ អោយក្លាយជាសិស្សរបស់ព្រះយេស៊ូ : គ្រូជំនួយជួយកុមារម្នាក់ៗរៀបចំផែនការសំរាប់ការងារអនុវត្តរបស់កុមារ (រាល់អាទិត្យ គ្រូបង្រៀន និង កុមារពិនិត្យមើលឡើងវិញ ពីការងារអនុវត្តសំរាប់អាទិត្យមុន) ។

នៅពេលបង្រៀន គ្រូបង្រៀនត្រូវប្រើសំនួរ ដែលត្រូវនឹងអាយុ
របស់កុមារ ។ ត្រូវសួរសំនួរ :

- ខ្លី ។
- ដែលមិនមែនត្រូវការតែចំលើយ «បាទ ឬ ចាស៎ » ឬ «ទេ »នោះទេ តែត្រូវការចំលើយដែលកុមារត្រូវពន្យល់ ។
- ដែលទាក់ទងនឹងសេចក្តី ដែលកុមារធ្លាប់ស្គាល់ ។
- ដែលលើកទឹកចិត្តកុមារអោយចេះប្រឌិត ដូចជា «បើសិនជាប្អូនជាកុមារនៅក្នុងរឿងនោះ តើប្អូននឹងធ្វើដូចម្តេច?» ។
- ដែលសួររកមូលហេតុ :«ហេតុអ្វីបានជានាងអេវ៉ាបរិភោគផ្លែឈើ ដែលព្រះជាម្ចាស់ហាមឃាត់ ? » ។
- ដែលនាំអោយក្មេងខំរកនឹក : «តើព្រះយេស៊ូធ្វើអ្វី នៅភូមិកាណាន ក្នុងស្រុកកាលីឡេ ? » ។

កុមារដែលអាយុតិចជាងដប់ឆ្នាំ តែងតែគិតទៅរកអ្វីៗដែលគេអាចមើលឃើញ ។ ឧទាហរណ៍ : បើសិនជាអ្នកប្រាប់កុមារថា៖ «ពេលចេញពីបង្គន់ កុមារត្រូវលាងដៃ ហើយមុននឹងញ៉ាំបាយ ឬ

ញ៉ាំចំណី កុមារត្រូវលាងដៃដែរ » បើដៃកុមារក្រខ្វក់ កុមារអាចទៅលាងដៃ តែបើដៃមិនប្រឡាក់ កុមារច្បាស់ជាគេចមិនលាងទេ ព្រោះគេគិតថាដៃគេស្អាត គ្មានមេរោគ ។ ប៉ុន្តែ បើប្រាប់កុមារ ហើយអោយរូបភាព ជាពិសេស គំនូរជីវចរអំពីមេរោគនៅក្នុងខ្យល់ អាកាស ពិសេស នៅក្នុងបង្គន់ ដែលអាចមកទំលើដៃកុមារដែលគ្មានប្រឡាក់អ្វី ហើយបណ្តាលឱ្យកុមារឈឺ នោះកុមារនឹងឧស្សាហ៍លាងដៃហើយ ។ ដូចគ្នានេះដែរ បើយើងនិយាយថា៖ «បើកុមារប្រជុំគ្នាសរសើរតម្កើងព្រះយេស៊ូ ព្រះអង្គនឹងគង់ជាមួយកុមារ ពេលនោះ » កុមារអាចឆ្ងល់ ព្រោះរកមើលមិនឃើញព្រះយេស៊ូ នៅក្នុងបន្ទប់ជាមួយពួកគេ ។ យើងត្រូវពន្យល់ថា ព្រះយេស៊ូប្រទានឱ្យព្រះវិញ្ញាណដ៏វិសុទ្ធមកគង់កណ្តាលចំណោមកុមារ ។ កុមារមិនអាចមើលឃើញព្រះវិញ្ញាណទេ ព្រោះព្រះអង្គគ្មានរូបកាយ ប៉ុន្តែកុមារដឹងថា មានព្រះវិញ្ញាណគង់ជាមួយ ព្រោះពេលសរសើរតម្កើងព្រះយេស៊ូ កុមារមានអំណរនៅក្នុងចិត្តណាស់ ។

ត្រូវប្រើពាក្យសំដី និង របៀបបង្រៀនដែលត្រូវនឹងអាយុរបស់កុមារ ។